# ខ្មែរឥស្សរៈ




ឥណ្ឌូចិនបារាំងសែស

## សរសេរ ដោយ ឧប សៅ សង្ហា

គ្មានរក្សាសិទ្ធិ អ្នកនិពន្ធ

# ខ្មែរឥស្សរៈ

មាតិការឿង

សេចក្ដីផ្ដើម ....................................................................................3
ក្រែកំណើត នៃ វរជនសេរី..........................................................................10
ប្រភព នៃ ការបំផុសគំនិត .......................................................................10
កំណើត នៃ គំនិត តស៊ូ នៅ ស្រុកខ្មែរ.............................................................15
គតិ នៃ ការសែត ‹នគរវត្ត›.......................................................................16
ជំហាន នៃ ការតស៊ូ..................................................................................22
កាលរាត្រី ថ្ងៃទី ៩ សីហា ឆ្នាំ ១៩៤៥ ..........................................................25
អ្នកណា ជា សត្រូវ នឹង អ្នកណា ?...............................................................27
ក្រឡេច របស់ បារាំង................................................................................30
ខ្មែរឥស្សរៈ..............................................................................................34
ខ្មែរយៀកមិញ .........................................................................................39
ការបែកបាក់គ្នា .......................................................................................43
វត្តមាន លោក សឺង ង៉ុកថាច់.......................................................................45
ទីចប់ .....................................................................................................48
ព្រះរាជបូជនីយកិច្ច ..................................................................................49
ករណី លោក សឺង ង៉ុកថាញ់ ......................................................................53
ឯកសារយោង.........................................................................................55

# ខ្មែរឥស្សរៈ

## សេចក្តីផ្តើម

ថ្ងៃ ទី១១ សីហា ឆ្នាំ ១៨៦៣ ព្រះរាជាណាចក្រខ្មែរ និង ប្រទេស បារាំង បាន យល់ព្រមគ្នា លើ សេចក្តី នៃ សន្ធិសញ្ញា ដាក់ ស្រុក ខ្មែរ ឱ្យនៅក្រោម អាណាព្យាបាល របស់ បារាំងសែស។ សន្ធិសញ្ញា នោះ ត្រូវបាន ហ្លួង នរោត្តម អោយសច្ចាប័ន នៅ ថ្ងៃ ទី១៧ មិថុនា ឆ្នាំ ១៨៦៤។ ព្រះមហាក្សត្រ អង្គដួង (១៨៤៥-១៨៦០) ដែល ជា បិតា ហ្លួង នរោត្តម ជា អ្នក មាន គំនិត ដំបូង តាម សំណូមពរ ព្រះសង្ឃ កាតូលិកបារាំងសែស មួយអង្គ នាម សម្តេច មីស។ ស្រុកខ្មែរ នៅ សម័យនោះ ស្ថិត នៅក្រោម ឥទ្ធិពល ប្រទេស សៀម ហើយ ទឹកដី កម្ពុជាក្រោម ត្រូវបាន ប្រទេសយួន គេ ត្រួតត្រា បានទាំងអស់។ ត្រូវកត់សម្គាល់ ថា ការឡើងគ្រង រាជសម្បត្តិ របស់ ហ្លួង នរោត្តម ត្រូវ បាន ព្រះអនុជ របស់ ព្រះអង្គ ព្រះនាម ស៊ីវុត្ថា ជំទាស់ ជា ដាច់ខាត ហើយ បង្កើត រណសិរ្សយោធា វាយប្រហារព្រះអង្គ ដែល នាំឱ្យទ្រង់ រត់ភៀសខ្លួន ទៅ ស្រុកសៀម (១៨៦១)។ ស្តេច សៀម ព្រះនាម Mongkut ធ្វើ អន្តរាគមន៍ ជួយ ហ្លួង នរោត្តម ឱ្យវិលត្រឡប់ មកគ្រងរាជ សម្បត្តិ នៅ ទីក្រុង ឧដុង្គ វិញ, ចំណែក ព្រះអង្គម្ចាស់ ស៊ីវុត្ថា ព្រះអង្គ ដកខ្លួន ទៅពួន នៅ ដំបន់ ព្រៃសាន នៃ ស្រុកខ្មែរ ហើយ នៅតែ ជំទាស់ ជម្លានរូប របស់ ព្រះរៀម រហូត ទ្រង់ ចូល មរណៈភាព នៅឆ្នាំ ១៨៩១។ នៅក្នុង បរិបទ ទាំងឡាយនោះឯង ដែល

## ខ្មែរឥស្សរៈ

នាំឱ្យ ហ្លួង នរោត្តម មាន ព្រះរាជហឫទ័យ បន្ត គំរោង របស់ ព្រះរាជបិតា ជាមួយ សម្តេច ម៉ឺស ដាក់ ស្រុកខ្មែរ ឱ្យនៅក្រោម អាណាព្យាបាល បារាំងសែស ដើម្បី ការពារ ព្រះរាជបល្ល័ង្ក របស់ ព្រះអង្គ។ ប៉ុន្តែ សន្ធិសញ្ញានោះ នាំឱ្យស្រុកខ្មែរ បាត់បង់ អធិបតេយ្យភាព នៃ កិច្ចការ ក្រៅប្រទេស តែ ទទួលបាន ពី សំណាក់ ប្រទេស បារាំង នូវ ការការពារ សន្តិសុខ ផ្ទៃក្នុង ហើយ នឹង ការឈ្លានពាន ពី ប្រទេស ជិតខាង។ សន្ធិសញ្ញានោះ ឃើញ ថា វា មាន ប្រយោជន៍ ពិតមែន ចំពោះ ព្រះរាជវាំង របស់ ហ្លួន នរោត្តម ព្រោះ នៅ អំឡុង ឆ្នាំ ១៨៦៤-១៨៦៦ និង ១៨៦៦-១៨៦៧ មាន កើត ឧទ្ទាមកម្ម នៅក្នុង ព្រះរាជាណាចក្រ ទី១ មាន មេដឹកនាំ ឈ្មោះ អាចារ្យ ស្វា និង ទី២ ឈ្មោះ ពោកំបោ។ ប៉ុន្តែ ឧទ្ទាមកម្មនោះ ត្រូវបានបង្ក្រាប បានរហ័ស ដោយ មាន ជំនួយ ពី កងទ័ព បារាំងសែស។ បន្ទាប់មក តាម ការស្នើ របស់ បារាំង ហ្លួង នរោត្តម ព្រះអង្គ សុខចិត្ត ប្តូរ រាជធានី ពី ក្រុង ឧដុង្គ មក ទីក្រុង ភ្នំពេញ ដែល ជា ទីកន្លែង អាច នាវាសមុទ្រ បារាំងសែស អាច ធ្វើចរាចរ មកដល់ គ្រប់ រដូវ។ ត្រូវ ដឹងថា បារាំង តែង មាន គោលបំណង យក ទន្លេ មេគុង ជា ផ្លូវទឹក សំរាប់ ធ្វើពាណិជ្ជកម្ម ជាមួយ ស្រុកចិន។ តែថា នៅ ឆ្នាំ ១៨៧០ ក្រោយ ពី បរាជ័យ នៃ បេសកកម្ម ដឹកនាំ ដោយ លោក Lagrée-Garnier រក មាត់ផ្លូវទឹក ទៅកាន់ ស្រុកចិន តាម ទន្លេ មេគុង ខាងលើ, ដូច្នេះ បារាំង ក៏គេធ្វើសេចក្តីសន្និដ្ឋាន ថា

ទន្លេ មេគុង មិនអាច ជា ផ្លូវទឹក សំរាប់ ធ្វើ ពាណិជ្ជកម្ម រវាង តណ្ឌូចិន និង ស្រុកចិន បាននោះឡើយ ព្រោះ វា មាន ឧបសគ្គ ធម្មជាតិ ច្រើនណាស់ ដែល នាវាសមុទ្រ ទ្រង់ទ្រាយធំ មិនអាច ធ្វើ ចរាចរ បាន។ ការបោះបង់ចោល គោលបំណងចមនោះ បារាំង បានងាក មក រក ទាញ ផលប្រយោជន៍ ពី ទឹកដី កម្ពុជា វិញ ដែល តម្រូវឱ្យ បារាំង បង្ខំ ហ្លួងខ្មែរ ប្រគល់ អំណាចឱ្យបារាំង ដឹកនាំផ្ទាល់ កិច្ចការ ផ្ទៃក្នុងខ្មែរ មួយចំនួន ដូចយ៉ាងក្នុង វិស័យ ហិរញ្ញវត្ថុ, ចូលរួមប្រជុំ គណរដ្ឋមន្ត្រី, កែទម្រង់ ច្បាប់ ភូមិបាល និង លុបបំបាត់ ទាសភាព ។ល។ ការក្រាញ របស់ ហ្លួងខ្មែរ នៅចំពោះមុខ អាជ្ញាធរ បារាំងសែស នាំឱ្យ បារាំង គំរាមដល់ ហ្លួងខ្មែរ ថា គេ នឹង ប្តូរ ឱ្យ ស្តេច ស៊ីសុវត្ថិ ជា ព្រះអនុជ ឡើងគ្រងរាជ្យ ជំនួស។ មិនតែ ប៉ុណ្ណោះ បារាំង កម្លា ដោយសម្ងាត់ ឱ្យ ព្រះអង្គម្ចាស់ ស៊ីវុត្ថា បះបោរ ជា ថ្មីម្តងទៀត ប្រឆាំងនឹង ហ្លួងខ្មែរ នៅ ឆ្នាំ ១៨៧៥ នៅ ព្រៃសាន ដើម្បី បារាំង ស្រួលស្នើ ដល់ ហ្លួងខ្មែរ ឱ្យដូរដោះ អន្តរាគមន៍ យោធា បារាំងសែស ជួយ ព្រះអង្គ នឹង រាជសិថិលភាព (concession royale) លើកំណែទំរង់របស់បារាំងសែស។ មកដល់ឆ្នាំ ១៨៧៩ ជនជាតិ បារាំង រស់នៅ កម្ពុជាក្រោម ជំរុញឱ្យ លោក Le Myre de Villers (១៨៧៩-១៨៨៣), អភិបាល នៃ កូសាំងស៊ីន[1], ធ្វើ

---

1 ពាក្យ កូសាំងស៊ីន។ ពាក្យនេះ មាន តម្លៃ បី យ៉ាង ខុសគ្នា នៅក្នុង អក្សរសិល្ប ភូមិសាស្ត្រ នៃ ជនជាតិ អឺរ៉ុប :

គ្រោងការណ៍ បញ្ចូល ស្រុកខ្មែរ មកក្នុង ទឹកដី កូសាំងស៊ីន តាម កលល្បិច បញ្ជូន ជនជាតិយួន ឱ្យមក រស់នៅ ស្រុកខ្មែរ ឱ្យបាន ច្រើនកុះករ រួចហើយ ទុកឱ្យ ជនជាតិយួន ទាំងនោះ លេប ស្រុកខ្មែរ តែម្តង។ ត្រូវដឹងថា នៅពេល ទ័ពបារាំង ចូលមកក្នុង ស្រុកយួន ហើយ វាយឈ្នះ ទ័ពយួន នៅ ដំបន់ កូសាំងស៊ីន ព្រះ ចៅយួន Tu Duc (១៨៤៧-១៨៨៣) នៅ ឆ្នាំ ១៨៦២ បាន

---

១. ពី ឆ្នាំ ១៥០២ ដល់ ១៦១៥ : កូសាំងស៊ីន កំណត់ នូវ រាជាអាណាចក្រ អណ្ណាម ទាំងមូល គឺ ខាងជើង ពី ព្រំដែន ចិន រហូត មក ខាងត្បូង ដល់ ព្រំដែន នគរ ចំប៉ា។
២. ពី ឆ្នាំ ១៦១៥ ដល់ ១៨៨២ : កូសាំងស៊ីន ជា ឈ្មោះ ភាគមួយ នៃ នគរ អណ្ណាម ដែល ស្ថិតនៅ ខាងត្បូង នៃ តុងកឹង ចន្លោះ ខាងជើង គឺ តំបន់ Dong Hoi និង ព្រំដែនខាងត្បូង នៃ អណ្ណាម (ព្រំដែន នោះ ចេះ តែ រំអិល ជានិច្ច ទៅ ទិស ខាង ត្បូង បណ្តាល អោយ ទឹកដី នៃ អណ្ណាម កាន់ តែ រិក ធំៗឡើង)។
៣. ពី ឆ្នាំ ១៨៨៣ ដល់ ១៨៨៧ : កូសាំងស៊ីន កំណត់ ដែនដី ឧបទ្វីប នៃ អាណានិគមបារាំង ខាងត្បូង ; រីឯ ភាគកណ្តាល បារាំង យក ឈ្មោះ ចាស់ អណ្ណាម សំរាប់ កំណត់ តែដែនដី ស្ថិតនៅ ត្រង់ ចន្លោះ តុងកឹង និង កូសាំងស៊ីន ដែល មួយ ភាគ ធំ ជា ទឹកដី នៃ អតីត នគរ ចំប៉ា។ ដូច្នេះ ចាប់ ពី ឆ្នាំ ១៨៨៣ បារាំង បែងចែក ទឹកដី អាណានិគមខ្លួន នៅ យៀកណាម ជា បី តំបន់ គឺ តុងកឹង, អណ្ណាម និង កូសាំងស៊ីន ដែល យើង យក មក ប្រើ រហូត មកដល់ សព្វថ្ងៃ នេះ សំរាប់ សំគាល់ ប្រទេស យៀកណាម។
ពាក្យ កូសាំងស៊ីន មាន ប្រភព ចេញ ពី ពាក្យ ជប៉ុន ដែល ហៅ នគរ អណ្ណាម ថា កូស៊ី គឺ មាន ន័យ ថា នគរ នៅ ភាគ មស្ចឹម នៃ នគរ ចិន ហើយ ពាក្យ នេះ ត្រូវបាន ពួកអ្នកជំនួញ Portugais គេ យក មក ប្រើ ដោយ បន្ថែមពាក្យ ស៊ីន (Chine) គឺ ថា កូស៊ីស៊ីន (កូស៊ី ភាគ ខាង ចិន) ដើម្បី មិន អោយ ច្រឡំគ្នានឹង ដំបន់ កូសាំង នៅ ឥណ្ឌា។ ពាក្យ នេះ គេ ចាប់ មាន ប្រើ ក្នុង មជ្ឈដ្ឋាន សាសនាកា តូលិញ នៅ ដើម សតវត្ស ទី ១៧, ហើយ សរសេរ អក្សរ ខុសគ្នាៗ ដូចយ៉ាង : Cocicina, Caucincina, Cauchina សំរាប់កំណត់ រាជាអាណាចក្រ ខាងត្បូង នៃ ពួក ងៀង ដែល ប្រឆាំងនឹង អំណាច ព្រះចៅ យួន អណ្ណាម។

ប្រគល់ ទឹកដី Bien Hoa, Gia Dinh[2], Vinh Tuong និង កោះត្រឡាញ គឺថា ទឹកដី កូសាំងស៊ីន មួយផ្នែក និង កម្ពុជាក្រោម ឱ្យបារាំង កាន់កាប់ ដាច់មុខ ហើយ ចាប់ពីពេលនោះមក បារាំង មិនដែល ទុក ទឹកដី កម្ពុជាក្រោម ជា របស់ ស្រុកខ្មែរ នោះឡើយ[3]។ ហេតុផល គឺ នៅ កម្ពុជាក្រោម មាន ជនជាតិខ្មែរ រស់នៅ តិចតួចណាស់ ដោយប្រៀបធៀបនឹង ជនជាតិយួន និង ចិន ហើយ កម្ពុជាក្រោម ស្ថិត នៅក្រោម អំណាច ព្រះចៅយួន តាំងពី ពាក់ កណ្ដាល សតវត្ស ទី១៧ មកម្លេះ។ ដូច្នេះ អាណានិគមនិយម បារាំងសែស នៅ ឥណ្ឌូចិន បានបែងចែក ដាច់ ស្រុកខ្មែរ ពី កម្ពុជាក្រោម។

ស្រុកខ្មែរ ស្ថិត នៅក្រោម អាណាព្យាបាល បារាំងសែស អស់រយៈពេល ៩០ ឆ្នាំ គឺ ពី ឆ្នាំ ១៨៦៣ ដល់ ១៩៥៣។ នៅក្នុង រយៈពេល នោះ មាន ស្ដេច គ្រងរាជ្យសម្បត្តិ ៤ ព្រះអង្គ គឺ ហ្លួង នរោត្តម (១៨៦០-១៩០៤), ស៊ីសុវត្ថិ (១៩០៤-១៩២៧)[4], ស៊ីសុវត្ថិ មុនីវង្ស

[2] ពាក្យ Gia Dinh ជា ពាក្យយួន ដែល គេ សំរាប់ប្រើ ហៅ ទឹកដី កម្ពុជា។

[3] ព្រះចៅយួន Tu Duc សុខចិត្ត ប្រគល់ ស្ទើរ ពាក់កណ្ដាល ដែនដី Cochinchine ឱ្យទៅបារាំង នៅ ថ្ងៃ ទី៥ កក្កដា ឆ្នាំ ១៨៦២ ព្រោះ ព្រះអង្គ ជួបប្រទះនឹង ការបះបោរ ពី សំណាក់ ពួក បក្សពួក នៃ សន្តតិវង្ស Lê នៅ Tonkin ប្រឆាំងនឹង ព្រះអង្គ ដែល មិនអាចឱ្យព្រះ ធ្វើសង្គ្រាម ប្រឆាំងនឹង បារាំងផង និង ពួកបះបោរផង។

[4] បន្ទាប់ពី ហ្លួង នរោត្តម សោយទីវង្គត ភ្លាមៗ លោក Lamothe, អគ្គនិវាសជន (résident supérieur) បារាំងសែស ប្រចាំនៅស្រុកខ្មែរ, ប្រជុំគណរដ្ឋមន្ត្រីខ្មែរ, ក្រុមបាគូរ និង ព្រះសង្ឃរាជ្យ ទាំងពីរ និកាយ ហើយ លោក ប្រកាស ដោយខ្លួនឯង តែងតាំង ព្រះ ឧបរាជ្យ ស៊ីសុវត្ថិ ជា ព្រះ

(១៩២៧-១៩៤១) និង នរោត្តម សីហនុ (១៩៤១-១៩៧០) (១៩៩៣-២០០៤)។ បន្តិចម្តងៗ លក្ខន្តិកៈ នៃ អាណាព្យាបាល បរិវត្ត ទៅជា របប អាណានិគមនិយម គឺ ស្រុកខ្មែរ ត្រូវបាន បារាំង គេ ត្រួតត្រា និង ដឹកនាំ ផ្ទាល់តែម្តង រហូត មកដល់ ឆ្នាំ ១៩៤៦។ អនុសញ្ញា[5] ថ្ងៃ ទី១៥ កក្កដា ឆ្នាំ ១៨៨៤ ហៅថា អនុសញ្ញា Thomson, ឈ្មោះ លោក អភិបាល កូសាំងស៊ីន, ជា អនុសញ្ញា អនុញ្ញាត ឱ្យ បារាំង មាន សេរីភាព គ្រប់បែបយ៉ាង ធ្វើការកែទម្រង់ និង បញ្ចប់ អំណាចប្រពៃណី របស់ព្រះមហាក្សត្រខ្មែរ នៅ ស្រុកខ្មែរ។ អនុសញ្ញា ថ្ងៃ ទី១៧ តុលា ឆ្នាំ ១៨៨៧ បារាំង បាន បញ្ចូល ស្រុកខ្មែរ ទៅក្នុង សហភាព ឥណ្ឌូចិន។ នៅ ថ្ងៃ ទី ១១ កក្កដា ឆ្នាំ ១៨៩៧ បារាំង បង្ខំ ហ្លួងខ្មែរ ឱ្យចុះហត្ថលេខា លើ បញ្ញត្តិ ប្តូរ ស្ថាប័ន នៃ ព្រះរាជាណាចក្រ។ សន្ធិសញ្ញា បន្ថែម ទាំងបីនេះ ដែល នាំឱ្យ ស្រុកខ្មែរ បាត់ឯករាជ្យជាតិ តែម្តង។

ពាក្យ អាណានិគមនិយម គឺ ជា មនោគមវិជ្ជា កើតឡើង នៅ សតវត្ស ទី១៩ នៅ អឺរ៉ុប ដើម្បី បង្ហាញ អំពី ភាពត្រឹមត្រូវ នៃ

---

មហាក្សត្រខ្មែរ បន្ត ពី សព ហ្លួង នរោត្តម ដោយ គ្មានការ ពិភាក្សា អ្វី បន្តិចឡើយ។

[5] ថ្ងៃទី១៧ មិថុនា ឆ្នាំ ១៨៨៤ បារាំង បានបង្ខំឱ្យហ្លួងនរោត្តម ចុះហត្ថលេខាលើសិទ្ធិសញ្ញា ប្រគល់រាជ្យអំណាចទាំងអស់ឱ្យដល់អភិបាលជាន់ខ្ពស់បារាំងនៅកម្ពុជា។ សន្ធិសញ្ញានេះ នាំបង្កើតការរប៉ះបោរពីសំណាក់ប្រជាពលរដ្ឋខ្មែរ រហូតដល់ឆ្នាំ ១៨៨៧ ឆ្នាំ ដែលបារាំង សុខចិត្ត ប្រគល់អំណាចឱ្យរដ្ឋបាលខ្មែរវិញ។ តែតាមការពិត បារាំងនៅតែបន្តត្រួតត្រារដ្ឋបាលនៅស្រុកខ្មែរដដែល។

# ខ្មែរឥស្សរៈ

អំពើ អាណានិគមនិយម គឺថា ការកេងប្រវ័ញ្ច ពី ទឹកដី ប្រទេស មួយ ពីសំណាក់ ប្រទេសមួយទៀត និង អនុញ្ញាតឱ្យ អាណិកជន របស់ខ្លួន ដែល មក តាំងទី នៅលើ ទឹកដីនោះ ស្វែងយក ផលប្រយោជន៍ ដាច់មុខ សំរាប់ខ្លួន។ មនោគមវិជ្ជា នេះ ប្រឆាំង ដាច់ខាតនឹង សិទ្ធិ របស់ ប្រជាពលរដ្ឋ ដែល អាច រៀបចំ វាសនាខ្លួន ដោយ ខ្លួនឯង។ ក្រោយពី សង្គ្រាម លោក លើកទី២ មក ពាក្យនេះ ត្រូវបាន ពួក បញ្ញវន្ត នៃ តតិយលោក ទុក ជា ពាក្យ ប្រមាថមើលងាយ ដល់ ប្រជាជន អាណានិគម ហើយ ប្រកាសប្រឆាំងនឹង ការបំពាន លើ សិទ្ធិ ប្រជាជន អាណានិគម ពីសំណាក់ ប្រទេស អាណានិគមនិយម, ទាមទារ ឱ្យមាន សិទ្ធិ ស្វ័យប្រណិធាន ដើម្បី សម្រេច លើ ជោគវាសនា របស់ខ្លួន និង បញ្ចប់ សម័យ នៃ ចក្រភព អាណានិគមនិយម នៅលើលោក។ សិទ្ធិ ស្វ័យប្រណិធាននេះ ត្រូវបាន អង្គការ សហប្រជាជាតិ ចារ នៅក្នុង ធម្មនុញ្ញ របស់ខ្លួន នៅឆ្នាំ ១៩៤៥។ ដូច្នោះឯង ក៏មាន ផ្ដួចផ្ដើម បង្កើត គំនិត និង ចលនា ទាមទារ ឯករាជ្យ និង សិទ្ធិ ស្វ័យប្រណិធាន នៃ ប្រជាពលរដ្ឋ នៅគ្រប់ប្រទេស ដែល កំពុង រស់នៅក្រោម អំណាច អាណានិគមនិយម នៅលើ ពិភពលោក។

# ខ្មែរឥស្សរៈ

## ក្រ៉ែកំណើត នៃ ទរជនសេរី

### ប្រភព នៃ ការបំផុសគំនិត

អាណាព្យាបាល ការពារ ដោយ អ្នក ដែល ពុំទុកខ្លួន ជា អ្នកឧបត្ថម្ភ តែ តាំងខ្លួន ជា ម្ចាស់ ពុំមែន ជា អាណាព្យាបាល នោះឡើយ។ ជាការពិត អស់រយៈពេល ៩០ ឆ្នាំ ដែល អាណាព្យាបាល បារាំងសែស នៅ ស្រុកខ្មែរ មាន ឥរិយាបទ ដូច្នោះ។ ក្នុងអំឡុងពេលនោះ វៀរលែងតែ ការរីកចំរើន កំរិតទាប ក្នុង វិស័យ សម្ភារៈ មួយចំនួន អាណានិគមនិយម បារាំងសែស ពុំបាន ធ្វើឱ្យសង្គមខ្មែរ កើតមាន គតិ ទំនើប ដែល ជា ចលករ នៃ ការរីកចំរើន របស់ ប្រជាជាតិ។ អំណាច នៃ អាណានិគមនិយមនេះគ្រាន់តែ មកត្រួតលើ អំណាច រាជាធិបតេយ្យ, ដូច្នេះ ចំពោះប្រជានុរាស្ត្រ គាត់ គ្មាន មើលឃើញ អ្វី ដែល ប្តូរមូល នៅក្នុងជីវិត រស់នៅ ជា ធម្មតា របស់ខ្លួន នោះឯង។ ផ្ទុយទៅវិញ គាត់រឹតតែ ខ្លាច រាជអំណាច ថែមទៀត ព្រោះ ដឹងថា មាន ទាហានបារាំងសែស ជា អ្នកការពារ។ ការខ្លបខ្លាចនេះ វា ឆ្លើយនឹង សេចក្តីត្រូវការ របស់ អាជ្ញាធរ បារាំងសែស ព្រោះ គេ ចង់បាន អកម្មភាព នៃ ប្រជាជន អាណានិគម នៅចំពោះមុខ អំណាចរបស់គេ។ ត្រូវដឹង ថា ទុក្ខភ័យ នៃ ប្រជានុរាស្ត្រ ពុំស្ថិត នៅលើតែ ភាពក្រីក្រ របស់ ប្រទេស នោះឡើយ ប៉ុន្តែ នៅលើ អកម្មភាព និង អលទ្ធភាព របស់ ប្រជានុរាស្ត្រ ប្រើ សមត្ថភាព របស់

ខ្លួន ដែលខ្លួនមាន ដើម្បី កម្រើក ចេញ ពី ទុក្ខភ័យនោះ ដោយខ្លួនឯង។ សុខចិត្តរស់ នៅក្នុង ភាពស្ងប់ស្ងាត់ នៅក្នុង ការរងគ្រោះ នៃ ទុក្ខវេទនា គ្រប់បែបយ៉ាង របស់ខ្លួន, សួរថា តើ ជាសិក្ខាបទ របស់ ព្រះសម្ពុទ្ធ សម្រាប់ ពុទ្ធបរិស័ទខ្មែរ ឬទេ ? ជាការមិនពិតឡើយ ដូចយ៉ាង ការបះបោរ នៃ ប្រជាពលរដ្ឋខ្មែរ នៅ ខែ មករា ឆ្នាំ ១៨៨៥ ប្រឆាំងនឹង សន្ធិសញ្ញា ឆ្នាំ ១៨៨៤ នៅ ឮសាន ដោយ មាន ជំនួយ ពី សៀម ពិតមែន បាន ធ្វើឱ្យបារាំងសែស គិតពិចារណា ឡើងវិញ លើ ចរិត ក្រអឺតក្រអោងរបស់ខ្លួន ហើយ តម្រូវ ឱ្យខ្លួន ធ្វើ សិថិលភាព នៃ ការកែទម្រង់របស់ខ្លួន មួយចំនួន ដែលប៉ះពាល់ ដល់ ប្រពៃណី នៃ សង្គមខ្មែរ ដើម្បី រក្សា សន្តិសុខ បានឡើងវិញ នៅស្រុកខ្មែរ។ ការបះបោរនោះ បង្ហាញ ឱ្យឃើញ ថា អ្វីដែលជា អត្តខ្លឹម នៃ ជាតិសាសន៍ខ្មែរ វាអាចខ្មែរ យកមកប្រើ ជា កម្លាំងតស៊ូ ដើម្បី ទុបទល់នឹងអំណាចបរទេស បាន។ តែ ការតស៊ូនោះ វាគ្មាន លក្ខណៈ ជា ការតស៊ូជាតិ អាចរក្សា ផ្វាលា[6] បានយូរអង្វែង ព្រោះ អំណាចបារាំងសែស គេ អាចជ្រែកចូល ទៅក្នុង ថ្នាក់ដឹកនាំខ្មែរ គ្រប់ស្រទាប់ ដែលនាំឱ្យខ្មែរ បាក់ សាមគ្គីជាតិ។

៥០ ឆ្នាំ ក្រោយមក គឺថា នៅ ឆ្នាំ ១៩៣៦ ទើបមាន ពន្លឺ នៃ សេចក្ដីសង្ឃឹមមួយ កើតចេញ ពីទឹកចិត្ត អ្នកចេះដឹងខ្មែរ មួយចំនួនតូច តែ ជា កម្លាំង គំរាម ដល់ អាជ្ញាធរ បារាំងសែស។ ន

---

66 ផ្វាលា : អណ្ដាតភ្លើង ឬ សេចក្ដីរុងរឿង។

រៈទាំងនោះ គាត់ មានដំណឹង ពីបរទេស អំពី ចលនា ប្រជាតស៊ូ កើតឡើង នៅ ដំបន់ អាស៊ី ដូចយ៉ាង ៖

១. ការប្រកាស របប សាធារណរដ្ឋ នៅ ស្រុកចិន នៅឆ្នាំ ១៩១២ ដែល ជា ការបង្ហាញ នូវ ទម្រង់ថ្មី នៃ ការសម្តែងគំនិត ជាតិនិយម និង សេរីភាព របស់ ប្រជាជនចិន។ លោក Sun Yat Sen ដែល ជា បិតា នៃ សាធារណរដ្ឋចិន បានបង្កើត គ្រឹះប្រជាជាតិចិនថ្មីមួយ ឈរលើ គោលការណ៍ បី យ៉ាង ៖ ជាតិនិយម, លទ្ធិប្រជាធិបតេយ្យ និង សង្គមនិយម។ លោក បានថ្លែង សុន្ទរកថា នៅ ថ្ងៃ ទី៦ មីនា ឆ្នាំ ១៩២៧ នៅក្នុង អង្គប្រជុំ នៃ គណកម្មធិការ ប្រតិបត្តិ នៃ គណបក្ស Kuo Min Tang ថា ៖ អ្វីដែល លោក ចង់បាន វាគ្មានអ្វីខុស ពី គំនិត របស់ លោកអតីត ប្រធានាធិបតី អាមេរិកាំង Lincoln នោះឡើយ គឺថា រដ្ឋាភិបាល នៃ ប្រជាពលរដ្ឋ ជ្រើសរើស ដោយ ប្រជាពលរដ្ឋ និង សំរាប់ ប្រជាពលរដ្ឋ ដែល លោក អតីត ប្រធានាធិបតី អាមេរិកាំង មួយទៀត Wilson យក មកធ្វើ ជា សព្ទសញ្ញា ៖ ប្រជាពលរដ្ឋ ទាំងឡាយ មាន សិទ្ធិ នឹង សម្រេច លើ ជោគវាសនា របស់ខ្លួន ដោយ ខ្លួនឯង។ លោក Sun Yat Sen បញ្ចប់ សុន្ទរកថា របស់ លោក ដោយ ធ្វើ សេចក្តីសន្និដ្ឋាន ថា គោលការណ៍ គ្រឹះ បីយ៉ាង របស់យើង គឺ មាន ន័យដូច្នោះ ទាំងស្រុង (Sic)។

យើង ធ្វើសង្ខេប នៃ អត្ថរស់ នៃ គោលការណ៍ ទាំងនោះ នៅ ខាងក្រោមនេះ :

## ខ្មែរឥស្សរៈ

**ជាតិនិយម** : ក្នុង គោលបំណង កសាង ឡើងវិញ នូវ កិត្យានុភាព នៃ ប្រជាពលរដ្ឋចិន ហើយនឹង បង្រួបបង្រួម គ្រប់ សាសន៍ជាតិ ដែល រស់នៅ ស្រុកចិន ឱ្យក្លាយ ជា ប្រជាជន តែមួយ នៃ ប្រជាជាតិចិន។

**លទ្ធិប្រជាធិបតេយ្យ** : ដើម្បី ស្ថាបនា លិទ្ធិនេះ ជា បឋម ត្រូវ ប្រកាន់យក សិទ្ធិ បួនយ៉ាង របស់ ប្រជាពលរដ្ឋ គឺ : សិទ្ធិបោះឆ្នោតផ្ទាល់, ការបោះឆ្នោតជាសាកល, ការធ្វើប្រជាមតិ, សិទ្ធិផ្តួចផ្តើមគំនិត និង សិទ្ធិ នៃការដកហូត អាណត្តិ និង អំណាច។

**សង្គមនិយម** : ការិយកម្ម[7] ទី១ គឺ ការចែក ដោយ ស្មើភាព ដី ដល់ កសិករ។ បន្ថយ គម្លាត រវាង អ្នកមាន និង អ្នកក្រ។ ធ្វើ ទំនើបកម្ម ឧបករណ៍ សំរាប់បង្កើតផល កសិកម្ម។ លើកទឹកចិត្ត ដល់ ការអភិវឌ្ឍន៍ ឧស្សហកម្ម។ រួមសេចក្តីមក គឺ ត្រូវ ធ្វើ អភិវឌ្ឍន៍ សេដ្ឋកិច្ច ដោយជៀសវាង កុំធ្វើកំហុស ដូច មហាអំណាច សេដ្ឋកិច្ច ធ្លាប់បានធ្វើ ពី អតីតកាល។

២. ពី ឆ្នាំ ១៨៧០ ប្រទេស ជប៉ុន ដែល ជា ប្រទេស អាស៊ី មាន ការរីកចំរើន និង ការអភិវឌ្ឍន៍ : ឧស្សាហកម្ម និង កសិកម្ម មាន ការជឿនលឿន ស្របគ្នា។ ការណ៍នោះ កើតឡើងបាន ដោយសារ អ្នកដឹកនាំ ជប៉ុន បោះបង់ របប សក្តិភូមិ ដោយ បើកទ្វារ ប្រទេស ដើម្បី ផ្សៀត យក បច្ចេកទេស ទំនើប នៃ

[7] ការិយកម្ម : កិច្ចការ។

ប្រទេសខាងលិច ដើម្បី ធ្វើអភិវឌ្ឍន៍។ ការរីកចំរើននេះ នាំឱ្យ ប្រទេស អាស៊ី ដទៃទៀត មើលឃើញ ជា ឱទាហរណ៍ ថា លទ្ធភាព នេះ វា អាច ជា គំរូ សំរាប់ខ្លួន។ មួយវិញទៀត នៅឆ្នាំ ១៩០៥ កងទ័ពជើងទឹក នៃ ចក្រភពជប៉ុន វាយឈ្នះ កងទ័ពជើងទឹក នៃ ប្រទេសរុស្ស៊ី ដែល ជា ជ័យជំនះ ដែល ប្រទេស អាស៊ី ទាំងឡាយ ទុក ជា មោទនភាព។

៣. នៅឆ្នាំ ១៩០០ នៅ ប្រទេស យួន មាន ការប្រយុទ្ធ គំនិត របស់ ពួក អក្សរសាស្ត្រ យួន ប្រឆាំងនឹង វត្តមាន បារាំងសែស នៅ ស្រុកយួន។ ការកម្រើក នៅក្នុង ផ្នែក គំនិតនេះ នៅឆ្នាំ ១៩២៦ នាំ មាន ការសរសេរ ថ្លែង អំពី ការទាមទារ របស់ ក្រុម អ្នកតស៊ូ មួយក្រុម ឈ្មោះ ‹សិទ្ធិ នៃ ជនជាតិ ម្ចាស់ស្រុក› ក្នុង នោះ មាន ៨ ចំណុច : ១. លើកទោស ជា ទូទៅ ដល់ អ្នកទោស នយោបាយ, ២. សម្ភាព នៃ សិទ្ធិ រវាង ជនជាតិ យួន និង បារាំងសែស នៅ ឥណ្ឌូចិន, ៣. សេរីភាព នៃ សារព័ត៌មាន និង ការបញ្ចេញ មតិ, ៤. សេរីភាព បង្កើត សមាគម និង ប្រជុំ, ៥. សេរីភាព នៃ ការធ្វើដំណើរ នៅក្នុង ប្រទេស និង ទៅ កាន់ ក្រៅ ប្រទេស, ៦. សេរីភាព នៃ ការសិក្សា និង បង្កើត សាលារៀន, ៧. ប្តូរ របប ក្រិត្យក្រម មក របប ច្បាប់, ៨. បង្កើត គណៈប្រតិភូ យួន ធ្វើ សហការ ជាមួយ រដ្ឋាភិបាល បារាំងសែស ដែល ទាក់ទងនឹង កិច្ចការ របស់ ប្រទេស យួន។ និវេទន៍នេះ ផ្សាយ ជា សាធារណៈ ក្រោយ ពី ហូ ជិញ មិញ ( ឈ្មោះដើម ង្វៀង អៃ

កុក) បង្កើត ចលនា តស៊ូ នយោបាយមួយ ឈ្មោះ ជា ពាក្យ កាត់ ថា ‹Than nien› ដែល ជា ស្នូល នៃ អនាគត នៃ គណបក្ស កុម្មុយនិស្ត ដែល បង្កើតឡើង នៅឆ្នាំ ១៩៣០។ នៅពេល ជាមួយគ្នា នោះដែរ ហូ បង្កើត កាសែត ប្រចាំសប្តាហ៍ លួចលាក់ មួយ អំពាវនាវ ដល់ ប្រជាពលរដ្ឋយួន ឱ្យមាន គំនិត ឯករាជ្យជាតិ និង ជាតិនិយម។ ប្រាំឆ្នាំ បន្ទាប់មក នៅ ថ្ងៃ ទី១៨ កុម្ភៈ ឆ្នាំ ១៩៣០ គណបក្ស កុម្មុយនិស្តយួន ដឹកនាំ ដោយ ហូ ផ្សាយ កម្មវិធី ធ្វើ សកម្មភាព ‹អប្បបរមា› មួយ របស់បក្ស ស្តីពី សកម្មភាព នៃ បដិវត្តន៍ ដែល មាន ការតស៊ូ ដើម្បី ឯករាជ្យ នៃ ឥណ្ឌូចិន ទាំងមូល។

## កំណើត នៃ គំនិត តស៊ូ នៅ ស្រុកខ្មែរ

ព្រឹត្តិការណ៍ នយោបាយ ប្រឆាំងនឹង អាណានិគមនិយម ដែលមាន កើតឡើង នៅក្នុង ដំបន់ អាស៊ី និង ឥណ្ឌូចិន វាជា សញ្ញាវិជ្ជមាន ទាក់ទាញ គតិ របស់ ខ្មែរ អ្នកជាតិនិយម មួយចំនួនតូច ដោយ មាន សេចក្តីសង្ឃឹម ថា អ្វី ដែល អាចកើតឡើង នៅ ប្រទេស ដទៃ វា ក៏អាច កើត បានដែរ នៅ ស្រុកខ្មែរ។ ដូច្នេះ នៅឆ្នាំ ១៩៣៦ មាន ខ្មែរ មួយក្រុម ដែល យើង អាច ទុកពួកគាត់ ជា ‹វរជនសេរី› ប្រមូលផ្តុំគ្នា ដើម្បី ពិភាក្សាគ្នា អំពីគ្រប់ បញ្ហា របស់ ស្រុកខ្មែរ ហើយ នាំគ្នា គិត ស្វែងរក ដំណោះស្រាយ។ ជនខ្មែរ ទាំងនោះ គាត់ រស់នៅ ក្នុង មជ្ឈដ្ឋាន ផ្សេងៗគ្នា តែ សព្វឹងគិត ទៅលើ គោលដៅ តែមួយ គឺ ឯករាជ្យជាតិ។

ពួកគាត់ ប្រជុំគ្នា ប្រមូលផ្តុំ បញ្ញារួម ប្រកបដោយវិធី នៃ ភាពច្នៃប្រឌិត ដើម្បី បង្កើត អាវុធ នយោបាយ និង ផ្លូវចិត្ត សំរាប់ ធ្វើឱ្យបាន សំរេច គោលដៅ កំណត់។ ការបង្កើត អាវុធនោះ គឺ ការបង្កើត កាសែត នយោបាយ សំរាប់ លើកកំពស់ ការយល់ដឹង របស់ ប្រជាពលរដ្ឋខ្មែរ ស្តីពី ឯករាជ្យជាតិ។ កាសែតនោះ មាន ឈ្មោះ ថា ‹ នគរវត្ត ›។ ឈ្មោះ នគរវត្តនេះ ពួក វរជនសេរី ចង់ បង្ហាញ សញ្ញា បីយ៉ាង ដល់ ប្រជាពលរដ្ឋខ្មែរ ៈ ១. ស្រុកខ្មែរ ធ្លាប់ ជា មហានគរ មាន វប្បធម៌ ខ្ពង់ខ្ពស់, ២. ប្រជាពលរដ្ឋខ្មែរ ជា អ្នកកាន់ ព្រះពុទ្ធសាសនា យល់ដឹង អំពី អ្វី ដែល ជា កុសល និង អកុសល ដែល នាំ ឱ្យខ្លួន ស្គាល់ អ្វី ដែល ជា ប្រយោជន៍ជាតិ អ្វី ដែល ជា ការកេងប្រវ័ញ្ច របស់ បរទេស, ៣. សារ នៃ សេចក្តីសង្ឃឹម ថា ខ្មែរ អាច ប្រមូលផ្តុំគ្នា ជា កម្លាំងជាតិ ដើម្បី ទាមទារ ឯករាជ្យជាតិ ពី អាណានិគមនិយម បារាំងសែស។

## គតិ នៃ កាសែត ‹នគរវត្ត›

នៅចំពោះមុខ ភាពគោកយ៉ាកលំបាក ជា ប្រក្រតី របស់ ប្រជានុរាស្ត្រខ្មែរ ពួក វរជនសេរី ចោទ ជា សំនួរ ថា ៈ អ្វីខ្លះ ជា មូលហេតុ ជាជម្រៅ នៃ ភាពគោកយ៉ាកលំបាក របស់ ប្រជាជន ?

ពួក អ្នកបដិវត្តន៍ នៅ ស្រុកចិន យល់ឃើញ ថា ‹សក្តិភូមិ› ដូច្នេះឯង បាន ជា លោក Sun Yat Sen គាត់ ប្តូរ របប រាជាធិបតេយ្យនិយម មក ជា របប សាធារណៈរដ្ឋ។ នៅ ប្រទេស ជប៉ុន ពួក អ្នកដឹកនាំ ថ្មី គេ បើកទ្វារ ប្រទេស ដើម្បី នាំចូល នូវ

បច្ចេកទេស ទំនើប សំរាប់ ធ្វើអភិវឌ្ឍន៍ នៅក្នុង គតិជាតិ ព្រោះ គេ យល់ថា បច្ចេកទេសនោះ ជា ឧបករណ៍ សំរាប់ បង្កើត ផល នាំឱ្យជាតិ ចំរើនកើន ដើម្បី លុបបំបាត់ ភាពក្រីក្រ របស់ ប្រជាជន។ នៅ ស្រុកយួន, ពួក អ្នកបដិវត្តន៍យួន យល់ឃើញ អាណានិគមនិយម ជា មេរោគ សម្លាប់ ប្រជាជាតិ ដូច្នេះ ត្រូវ ប្រជាជនយួន ងើបប្រឆាំងនឹង អកុសលនេះ ដើម្បី សេចក្តីរង់ រឿង នៃ ប្រជាជាតិយួន។ រីឯ នៅ ស្រុកខ្មែរ វិញ ពួក វរជនសេរី មាន គតិគោល ថា ស្រុកខ្មែរ មិនដូច ស្រុកចិន, មិនទាន់មាន សមត្ថភាព ដូច ប្រទេស ជប៉ុន និង កំពុង រស់នៅក្រោម អាណានិគមនិយម បារាំងសែស ដូច ស្រុកយួន ដែល គេ មាន ចំនួន ប្រជាជន ច្រើន (២០ លាន នាក់), ជា ប្រជាជន មាន គុណសម្បត្តិ ជា ជាតិសាសន៍-ទាហាន ដែល អាច ជ្រើសយក ការតស៊ូ ប្រដាប់អាវុធ ប្រឆាំងនឹង បារាំង, ហើយ គេ មាន បញ្ញាវន្ត មួយចំនួន ត្រៀមខ្លួន ស្ម័គ្រចិត្ត រួចរាល់ហើយ ធ្វើ ការ តស៊ូ ដ៏ពិបាក និង យូរអង្វែង ដើម្បី ឯករាជ្យ និង ឯកភាព នៃ ប្រជាជាតិយួន។ ដឹងខ្លួន អំពី ភាពមិនដូចគ្នា នោះឯង ដែល វរជនសេរីខ្មែរ ជា អ្នកដឹកនាំចម្បង នៃ កាសែត នគរវត្ត ដូច មាន លោក សឺង ង៉ុកថាញ់, ប៉ាច ឈឺន, អៀវ កើស, ស៊ឹម វ៉ា, ងោ ហុង, ជុំ មួន និង នួន ដួង នាំគ្នា ជ្រើសរើស ផ្លូវ តស៊ូមួយ ដោយ ឈរ លើ កម្លាំង ប្រពៃណីខ្មែរ ដើម្បី ឯករាជ្យជាតិ។ កម្លាំងនោះ មាន : រាជានិយម ជា តំណាង នៃ ប្រពៃណីជាតិ, ព្រះពុទ្ធ

# ខ្មែរឥស្សរៈ

សាសនា ជា តំណាង នៃ ប្រជាពលរដ្ឋខ្មែរ និង អ្នកចេះដឹកខ្មែរ ជា តំណាង នៃ ភាពទំនើប។ ការផ្តុំ កម្លាំងទាំងបីនេះ ឱ្យទៅជា កម្លាំងជាតិ វាជា អាវុធ នយោបាយ សំរាប់ ការតស៊ូ ប្រឆាំង នឹង អាណានិគមនិយម បារាំងសែស។ នៅត្រង់ចំណុចនេះឯង ពួក វរជនសេរី មិនដែល មាន គំនិត ប្រឆាំងនឹង រាជានិយម នោះឡើយ ផ្ទុយទៅវិញ តែងតែទុក របបនោះ ជា សមាសភាព ដ៏សំខាន់មួយ នៃ កម្លាំងតស៊ូជាតិ។ រឿងមួយ ដែល យើង លើក យកមក បញ្ជាក់ លើ ចំណុចនេះ គឺ កន្សីកម្ម របស់ លោក កេង វ៉ាន់ សាក់ : នៅពេល ដែល លោក សឺង ង៉ុកថាញ់ ត្រូវ បារាំង ចាប់ យកទៅ ឃុំ នៅ ស្រុកបារាំង ក្រោយពី សង្គ្រាមលោក លើកទី២ លោក កេង វ៉ាន់ សាក់ ជា និស្សិត បានទៅជួប សួរ សុខទុក្ខ លោក សឺង ង៉ុកថាញ់ ហើយ តែងតែ ពិភាក្សាគ្នា អំពី រឿងនយោបាយជាតិ, ចំពោះ លោក សឺង ង៉ុកថាញ់ គាត់ មិន ដែល លើកយក របប សាធារណរដ្ឋ មកធ្វើជា គោលគ្រឹះ នយោបាយ របស់គាត់នោះឡើយ។ អ្វី ដែល សំខាន់ សំរាប់គាត់ គឺ មាន តែ ឯករាជ្យជាតិ តែមួយគត់។ ដូច្នេះ ការចាំបាច់ គឺ ការរួបរួម គ្រប់ កម្លាំងជាតិ ដើម្បី ដើរ ទៅរក គោលដៅ តែ មួយនោះឯង។

ពួក វរជនសេរី យល់ឃើញ ថា ប្រជាបញ្ហា វាកើតចេញ ពី សកម្មភាពតស៊ូ។ ហើយ សកម្មភាពនេះឯង ជា បឋម គឺ មុខ តំណរ តភ្ជាប់ រវាង កម្លាំង ទាំងបីនោះឯង ដើម្បី យកមក ធ្វើ

## ខ្មែរឥស្សរៈ

ជា មធ្យោបាយ ក្នុង សកម្មភាពតស៊ូ។ សកម្មភាព ត្រូវមាន ដំណើរ គណ្ឋិកៈ[8] ហួរហែ ដូចតទៅ : ផ្សាយ សារ សាមញ្ញ ដល់ ប្រជានុរាស្ត្រ សំរាប់ លើក កំពស់ ការយល់ដឹង អំពី ខ្លឹមសារ នៃ ឯករាជ្យជាតិ, ដំណាក់ការ ជា កាចាំបាច់ ដើម្បី ស្ថាបនា កម្លាំង រួបរួមជាតិ។ ន័យ ក្នុង សារនោះ គឺ :

- សាមគ្គី ជា កម្លាំងជាតិ;
- ស្រុកខ្មែរ ត្រូវការ ដើបឈរ, ភាពទំនើប និង ការប្រែខ្លួន ដោយ ផ្អែក លើ កម្លាំងជាតិ ដើម្បី ការរីកចំរើន;
- អនាគតជាតិគឺនៅក្នុងកណ្តាប់ដៃ របស់ប្រជាពលរដ្ឋខ្មែរ;
- ប្រពៃណីជាតិ វា មាន តម្លៃ ច្រើនជាង វិធីបរទេស;
- ខ្មែរ សព្វថ្ងៃ គឺ គ្រាន់តែជា ស្រមោល នៃ បារាំងសែស នៅ ឥណ្ឌូចិន ហើយ នាំគ្នា រស់រំពឹង លើ តែ បារាំង ទាំងស្រុង។

ពួក អ្នកសរសេរ សុទ្ធ ជា អ្នក មាន កោសល្យ ខាង និពន្ធ ដូច មាន ភិក្ខុ ប៉ាង ខាត់, ហែម ចៀវ, ខៀវ ជុំ និង គ្រហស្ថ មាន លោក ស៊ឹម វ៉ា, ទេព ប៉ាន់, ផៀង លៀង, ម៉ិញ ណាគ្រី និង អស់ អ្នកនិពន្ធ មួយចំនួនទៀត ដែល ស្ម័គ្រចិត្ត ចូលរួម ចំណែក ក្នុង ការតស៊ូ គំនិត ដើម្បី ជាតិ។ វរជនសេរី ទាំងឡាយនោះ ធ្វើ សកម្មភាព លួចលាក់ ប្រឆាំងនឹងបារាំងក្នុងអំឡុង ឆ្នាំ ១៩៣៦ ដល់ ១៩៤២ ដើម្បី ផ្តល់ នូវ សេចក្តីសង្ឃឹម ដល់ ប្រជាពលរដ្ឋខ្មែរ ឱ្យមាន ជំនឿ លើខ្លួនឯង ដើម្បី កសាង វាសនា ដ៏ល្អប្រសើរ

---

[8] គណ្ឋិកៈ : ដែលមានសន្លាក់, articulé.

របស់ខ្លួន ដោយខ្លួនឯង ក្នុង ស្រុកខ្មែរ ឯករាជ្យ សំរាប់ ជន ជាតិខ្មែរ។ ពួក គាត់ តែងតែ មក ជួបជុំ ពិភាក្សាគ្នា នៅក្នុង ហាង កាហ្វេមួយ ដែល មាន លោក ប៉ុណ្ណចន្ទ ម៉ុល ជា ម្ចាស់ ហាង[៩]។ ហាងកាហ្វេនោះ ក្លាយ បន្តិចម្ដងៗ ទៅជា កន្លែង អ្នក ស្នេហាជាតិ មកជួបជុំគ្នាដើម្បី ប្រឹក្សាគ្នា អំពីនយោបាយស្រុក។ ភាពរីកវរនោះ នាំឱ្យ អាជ្ញាធរបារាំង គេ មាន ការសង្ស័យ ហើយ គេ ឱ្យ គិញ របស់គេ មកស៊ើប, តែ ម្ចាស់ហាង ដឹងរឿង នេះ ក៏ធ្វើជាសញ្ញាមួយ សំរាប់ ជូនដំណឹង ដល់ អ្នកស្នេហាជាតិ ថា មាន គិញបារាំង នៅក្នុងហាង, សញ្ញានោះ គឺ រូបចម្លាក់ឈើ ក្បាលឆ្កែ ដាក់លើតុមួយ, ដូច្នេះ កុំនាំគ្នា ជជែក ពីរឿង នយោបាយ។

កាសែត ‹ នគរវត្ត › មាន ការគាំទ្រ ពីសំណាក់ ព្រះអង្គម្ចាស់ ពីណារា, អនុជ ហ្លួង មុនីវង្ស, ព្រះអង្គ ជួយ ជំនួយប្រាក់ ១000 រៀល។ លោក ប៉ាច ឈឺន, ចាងហ្វាងកាសែត, អញ្ជើញទៅ ទទួលប្រាក់ ពីព្រះហស្តព្រះអនុជផ្ទាល់។ កាសែតនោះ មាន ប្រជាប្រិយភាព ខ្លាំងណាស់ រហូត បង្កើន ចំនួន បោះពុម្ព ពី ៥00 ក្បាល

---

[៩] អ្នកមាន គំនិត បង្កើត ហាងកាហ្វេនោះ គឺ លោក ប៊ុន ចាន់ គឺ ដើមឡើយ លោក មាន គំនិត ជួយ មិត្តលោកម្នាក់ ឈ្មោះ ប៉ុណ្ណចន្ទ ម៉ុល ដែល ជា កូនប្រុស របស់ ឧកញ្ញា ហើយ ជា កូនប្រសារ របស់ មហាមន្ត្រី ប៉ុក ដុច។ បុរសនោះ គ្មាន ការធ្វើ តែ ចូលចិត្ត កីឡា ប្រដាល់ ល្បីល្បាញម្នាក់ នៅ ក្រុង ភ្នំពេញ។ ហាងកាហ្វេ ជា ក្រុមហ៊ុន របស់ មនុស្សបីនាក់ ប៊ុន ចាន់, ប៉ុនណា និង ប៉ុណ្ណចន្ទ ម៉ុល។ លោក ដាក់ ហ៊ុន ៣00 រៀល រីឯ អ្នកទាំងពីរនោះ ដាក់ ហ៊ុន ២00 រៀល។

# ខ្មែរឥស្សរៈ

ក្នុងមួយសប្តាហ ទៅ ៧០០០ ក្បាល មួយសប្តាហ។ ឃើញដូច្នេះ អាជ្ញាធរបារាំងសែស ចាប់ផ្តើម ធ្វើការត្រួតពិនិត្យន័យ នៃ អត្ថបទ មុននឹងឱ្យ ចុះផ្សាយ។ បារាំង គេ រករឿង គ្រប់បែប យ៉ាង ដើម្បី ពន្យារពេល បោះពុម្ពផ្សាយ។ ពីរខែក្រោយមក អាជ្ញាធរបារាំងសែស គេ មកចាប់ ភិក្ខុ ហែម ចៀវ, លោក ជុំ មួន និង នួន ដួង ពី សាលា បាលី ជាន់ខ្ពស់។ ប៉ូលីសបារាំងសែស នាំ ភិក្ខុ ហែម ចៀវ ទៅ ក្រសួង មហាផ្ទៃ រួចតម្រូវឱ្យ លោក ទៀ សាន ជា រដ្ឋមន្ត្រី ធ្វើ ពាក្យសុំ ជា បន្ទាន់ ទៅ សម្តេច ជួន ណាត ដើម្បី ដាក់ផ្នួស ភិក្ខុ ហែម ចៀវ។ មុន នឹងចាប់ ភិក្ខុ ហែម ចៀវ មាន ជនជាតិ បារាំងសែសម្នាក់ ឈ្មោះ Pathé បានសុំ សម្តេច ជួន ណាត បួស នៅ វត្ត លង្កា។ តាមពិត លោក Pathé នោះ ជា គិញ បារាំងសែស គាត់ មកស៊ើប សកម្មភាព ប្រឆាំងបារាំង នៅក្នុង វត្ត។ ភិក្ខុ ហែម ចៀវ ដឹង ការណ៏នេះ បាន ជូន ដំណឹង ដល់ សម្តេច ជួន ណាត តែ សម្តេច មិន ជឿ ហើយ ឆ្លើយប្រាប់វិញ ថា ព្រះអង្គ ស្គាល់ លោក Pathé នេះ ច្បាស់ ណាស់, សុំ ភិក្ខុ កុំបារម្ភ អ្វីឡើយ។ ភិក្ខុ ហែម ចៀវ ឆ្លើយតប ទៅ សម្តេចវិញ ថា : អាត្មា ជា មនុស្សល្ងង់ ប៉ុន្តែ តែងតែ ស្តាប់ ការទូន្មាន របស់ សម្តេច ជានិច្ច គឺ ព្រះអង្គ តែងតែឱ្យ ឱវាទ ថា កុំឱ្យទុកចិត្ត ជនជាតិ បារាំងសែស ឱ្យសោះ។

## ជំហាន នៃ ការតស៊ូ

ទង្វើ របស់ អាជ្ញាធរ បារាំងនោះ នាំដុត កំហឹង នៃ ពួក វរជន សេរី ហើយ មិនព្រម ទូទុក្ខនេះ ក៏នាំគ្នា រៀបចំ ធ្វើសកម្មភាព ឆ្លើយតបវិញ គឺ គម្រោង ធ្វើបាតុកម្ម ទាមទារឱ្យ បារាំង ដោះលែងភ្លាម ភិក្ខុ ហែម ចៀវ, លោក ជុំ មួន និង នួន ដួង គ្មានលក្ខខណ្ឌ។ នរះទាំងឡាយនោះ ធ្វើការប្រមូលខ្មែរ ដោយ សម្ងាត់បំផុត ទាំង ភិក្ខុ ទាំង គ្រហស្ថ ដើម្បី ធ្វើដំណើរទួម[10] ជា មហាយាត្រា ប្រឆាំងនឹង ទង្វើ របស់បារាំង។ ពួកគេ នាំគ្នា បែងចែក ជាក្រុម ធ្វើ បដា, ចែក ខិត្តប័ណ្ណ តាម វត្តអារាម។

ថ្ងៃ ទី២០ កក្កដា ឆ្នាំ ១៩៤២ ជា ថ្ងៃ ជ័យ សំរាប់ អ្នកតស៊ូខ្មែរ ប្រមាណ ជាង មួយពាន់នាក់ មាន លោក ប៉ាច ឈឺន និង សឺង ង៉ុកថាញ់ នាំមុខ ដើរ ជា ក្បួនដង្ហែ មាន ចម្ងាយ ប្រមាណ ១ គីឡូម៉ែត្រ ចេញពី វត្តលង្កា ហែ រជយ[11] លើក បដា កាត់ អនុវិទ្យាល័យ ស៊ីសុវត្ថិ ឆ្ពោះ ទៅកាន់ អគ្គនិវាសដ្ឋាន បារាំងសែស នៅ ក្បែរ វត្តភ្នំ។ នៅទីនោះ មាន ក្រុម ប៉ូលិស បារាំងសែស (ច្រើនតែ ជនជាតិយួន) ឈរចាំ ពួក បាតុករ។ ទៅដល់ភ្លាម លោក ប៉ាច ឈឺន អាន សំណើ ដល់ អាជ្ញាធរ បារាំងសែស សុំឱ្យ ដោះលែង ជា បន្ទាន់ និង គ្មាន លក្ខខណ្ឌ ភិក្ខុ ហែម ចៀវ, លោក ជុំ មួន និង នួន ដួង។ ប៉ុន្តែ អាជ្ញាធរ បារាំងសែស គេ

---

10 ទួម : គុ. ដែលចូលរួម។
11 រជយ : ជាជួរ។

ហាក់បី ធ្វើមិនឮ ដែល នាំឱ្យ លោក ប៉ាច ឈឺន អាន ហើយ អានទៀត។ បន្តិច ក្រោយមក ពួក ប៉ូលិស នាំគ្នា មកឈរព័ទ្ធ ជុំវិញគាត់ រួចហើយ មេ ប៉ូលិស លើក កាំភ្លើងដៃ កំហែងគាត់ ថែមទៀត ដែលនាំឱ្យពួក បាតុករ ជា ពិសេស នៅជួរមុខ រុល ទៅមុខ ញីករទើសគ្នា ដើម្បី ចង់ជួយ លោក ប៉ាច ឈឺន។ ខណៈ ពេលនោះ ព្រះសង្ឃ យក ឆត្រ បុក ញាប់រទេញ ពួក ប៉ូលិស ហើយ ពួកនោះ ក៏យក ដំបង វាយតបវិញ គ្មានសំចៃដៃ, នៅ ពេលនោះ លោក ប៊ុណ្ណចន្ទ ម៉ុល ក៏លើក កង់ របស់លោក បោះ ទៅលើ ពួក ប៉ូលិស។ ដោយ យល់ឃើញ ថា ស្ថានការណ៍នេះ នឹង នាំមក នូវ សេចក្តីគ្រោះថ្នាក់ ដល់ពួកខ្លួន មេ ប៉ូលិស បារាំងសែស ក៏ បាញ់ ទៅលើ បីបួន គ្រាប់ ដើម្បី បំភ្លាំង ពួក បាតុករ។ គ្រាន់តែ ឮ ស្នូរកុងៗភ្លាម ពួក អ្នកបះបោរ ក៏នាំគ្នា រត់ខ្ចាត់ខ្ចាយ... 

ពេលរាត្រីមកដល់ អាជ្ញាធរ បារាំងសែស តាមស្វែងរកចាប់ ពួក មេបះបោរ គ្រប់ ទីកន្លែង នៅ ក្រុងភ្នំពេញ។ ភិក្ខុ ប៉ាង ខាត់ និង លោក ប៊ុណ្ណចន្ទ មុល ត្រូវបាន ប៉ូលិស ចាប់បាន មុន គេបង្អស់។ ចំណែក លោក សឺង ង៉ុកថាញ់ គាត់ រត់ទៅពួននៅ អគ្គសេនាធិការ នៃ កងទ័ពជប៉ុន[12]។ អាចារ្យ សុខ នឹង ឈៀង

[12] នៅថ្ងៃ ទី៩ មីនា ឆ្នាំ ១៩៤១ របប Vichy នៅ ប្រទេស បារាំង បាន យល់ព្រមនឹង ប្រទេសជប៉ុន (អនុសញ្ញា ឈ្មោះ ក្រុងតូក្យូ) ឱ្យសិទ្ធិ កងទ័ព ជប៉ុន ប្រើប្រាស់ ទឹកដី ឥណ្ឌូចិន ជា មូលដ្ឋានយោធា សំរាប់ វាយ ប្រហារ កងទ័ព អង់គ្លេស នៅ ប្រទេសម៉ាឡេស៊ី។

លៀង នាំគ្នា រត់ទៅ ស្រុកសៀម, រីឯ លោក ប៉ុន ថាន់ គាត់ រត់ទៅពួន នៅស្រុក ស្វាយពល ក្នុង ខេត្តព្រៃវែង ហើយ អស់អ្នកតស៊ូ ដទៃទៀត ក៏នាំគ្នា រត់គេចខ្លួន រកកន្លែង សុវត្ថិភាព រៀងៗខ្លួន នៅក្នុង ព្រះរាជាណាចក្រ។ បន្ទាប់មក ប៉ូលិស បារាំងសែស បានទៅ វាយកំទិច រោងបោះពុម្ព កាសែត នគរវត្ត។ នៅថ្ងៃ ទី ១៩ ធ្នូ ឆ្នាំ ១៩៤២ តុលាការសឹក បារាំងសែស នៅ ព្រៃនគរ បាន កាត់ទោស ភិក្ខុ ហែម ចៀវ និង លោក ប៊ុណ្ណ ចន្ទម៉ុល ដាក់គុក នៅ កោះត្រឡាច, រីឯ ភិក្ខុ ប៉ាង ខាត់ និង អ្នកតស៊ូ មួយចំនួន នៅ ពន្ធនាគារ នៅ ព្រៃនគរ។ ៦ ខែ បន្ទាប់មក ភិក្ខុ ហែម ចៀវ បាន ចូលអនិច្ចកម្ម ដោយសារជំងឺ គមរមាស់ ដោយសារ គ្មានការព្យាបាល ពីសំណាក់អាជ្ញាធរ នៃពន្ធនាគារ។ លោក សឺង ង៉ុកថាញ់ បាន ជប៉ុន ជម្លៀស ទៅស្រុកគេ ហើយ បាន ចុះឈ្មោះចូលរៀន នៅ មហាវិទ្យាល័យ ‹ មហា អាស៊ី › នៅ ទីក្រុង តូក្យូ។

ទោះបី ទុក ជា បរាជ័យ តាមផ្លូវ កម្លាំងបាយ តែ វា ជាជោគជ័យ តាមផ្លូវ ទឹកចិត្ត។ ជាការពិតហើយ កាសែត នគរវត្ត ត្រូវ បារាំង ផិតកប់ តែ មិនអាច បញ្ចប់ វិត្ថារកម្ម នៃ គតិស្នេហាជាតិ របស់ កាសែត បាននោះឡើយ។ ពាក្យពេចន៍ ដែលធ្លាប់បានអាន វា ជ្រាប ហើយ ផ្តិត ក្នុង សតិ អ្នកស្នេហាជាតិ ហើយ ឈ្មោះ វរជនសេរី ដូចយ៉ាង ភិក្ខុ ហែម ចៀវ, ប៉ាង ខាត់, លោក ប៉ាច ឈឿន, សឺង ង៉ុកថាញ់ ។ល។ វា ប្រែ ទៅ ជា និមិត្តរូប

ពិត នៃ ការតស៊ូ ដើម្បី ឯករាជ្យជាតិ។ ថ្វីត្បិត លោក ទាំងឡាយ រស់នៅឆ្ងាយ ពី មាតុភូមិ ក្តី នៅក្នុង ពន្ធនាគារ ក្តី នៅទីកន្លែង សម្ងាត់ ក្តី តែនៅក្នុង ស្មារតី របស់ អ្នកស្នេហាជាតិ ពួកលោកទាំងនោះ គាត់នៅតែ ជា មហាបុរសជាតិ និង ជា មាគ៌ា នៃ អនាគត របស់ ប្រជាពលរដ្ឋខ្មែរ។ ការបង្ក្រាប នៃ អាជ្ញាធរបារាំងសែស មកលើ ពួក អ្នកស្នេហាជាតិ ជា ភ្លើង ក្តៅ ពិត តែវា ក៏មិនរលាក បេះដូង នៃ នរៈទាំងឡាយនោះដែរ។ ផ្ទុយទៅវិញ ភ្លើងនោះ វា បែរ ជា រក្សា កំដៅ ទឹកចិត្ត ជា កូនខ្មែរ ស្រឡាញ់ជាតិ គ្មាន បារាំង ជា ម្ចាស់ស្រុក។

៣ ឆ្នាំ ក្រោយមក នៅថ្ងៃ ទី៩ មីនា ឆ្នាំ ១៩៤៥ កងទ័ព ជប៉ុន នៅ ឥណ្ឌូចិន សម្រេច ចាប់ ជនជាតិបារាំង ទាំងអស់ រស់នៅទីនោះ, បន្ទាប់មក ស្នើ ឱ្យប្រទេស ខ្មែរ យួន និង លាវ ប្រកាស ឯករាជ្យ[13]។ នៅស្រុកខ្មែរ ហ្លួង សីហនុ ប្រកាស ឯករាជ្យ នៅថ្ងៃ ទី ១២ មីនា។ បន្ទាប់មក ជប៉ុន នាំ លោក សឺង ង៉ុកថាញ់ មក ស្រុកខ្មែរ វិញ។

### កាលរាត្រី ថ្ងៃទី ៩ សីហា ឆ្នាំ ១៩៤៥

ហ្លួង សីហនុ រៀបចំ ការប្រជុំគ្នាលេង (surprise-partie) មួយ នៅក្នុង ព្រះបរមរាជវាំង ពេលនោះ មាន វត្តមាន លោក សឺង

[13] ថ្ងៃ ទី១០ មីនា ១៩៤៥ ប្រទេសលាវ បាន ប្រកាស ឯករាជ្យ, ចំណែកឯ ព្រះចៅ បាវ ដាវ នៃ ស្រុកយួន បាន ប្រកាស ឯករាជ្យ នៅថ្ងៃ ទី ១១ មីនា ឆ្នាំ ១៩៤៥។

# ខ្មែរឥស្សរៈ

ង៉ុកថាញ់ ដែរ។ ស្រាប់តែ មាន យុវជន ៧ នាក់ ប្រដាប់ ដោយ អាវុធ មាន ឈ្មោះ ម៉ៃ ផូ, ណែត ឡាំងសាយ, ម៉ម ក្មួន, ម៉ៅ សារុ ទ, ហែម សាវ៉ាន់, គីម អាន ដួរ និង ថាច់ សារី លួច ចូលវាំង បាន នាំ ឱ្យមាន ផ្ទុះអាវុធ ដែល បណ្តាល ឱ្យលោក នង គីមនី មាន របួស ព្រោះ លោក ត្រូវ គ្រាប់ ពីរបីគ្រាប់ តែ មិនស្លាប់។ ន រៈទាំងនោះ ចាប់ ហ្លួង សីហនុ បាន ហើយ បង្ខំ ឱ្យព្រះអង្គ ដាក់ រាជ្យ ដើម្បី ប្រកាស សាធារណរដ្ឋ។ ប៉ុន្តែ លោក សឺង ង៉ុកថាញ់, ប្រហែល ជា មេ របស់ ពួកនោះផង, ក៏បាន ចូលមកជួយ ហើយ ធ្វើកិច្ចព្រមព្រៀង ជាមួយ ហ្លួង សីហនុ នៅ ពេលនោះ ដោយ យល់ព្រម ពី ហ្លួង តែងតាំង លោក ជា រដ្ឋមន្ត្រី ទី១ នៃ ព្រះរាជា ណាចក្រកម្ពុជា។ ហេតុនេះហើយ នៅថ្ងៃ ទី ១៦ សីហា ឆ្នាំ ១៩៤៥ លោក សឺង ង៉ុកថាញ់ ត្រូវបាន ហ្លួង សីហនុ តែងតាំង ជា រដ្ឋ មន្ត្រី ទី១ និង រដ្ឋមន្ត្រី ក្រសួង ការបរទេស[14]។ ជាការពិតហើយ អ្វី ដែល អាច កើតមានបាននៅពេលនោះ គឺ មាន ការ ឧបត្ថម្ភ ពី កងទ័ពជប៉ុន ព្រោះលោក សឺង ង៉ុកថាញ់ ជាមនុស្ស សំណប់របស់ជប៉ុន។

---

[14] គណរដ្ឋមន្ត្រី របស់លោក សឺង ង៉ុកថាញ់ មានឥស្សរជនសំខាន់ៗ មួយ ចំនួន ដូចជា៖ លោក ប៉ែន នុត ជា រដ្ឋមន្ត្រីក្រសួង ហិរញ្ញវត្ថុ, លោក ញឹក ជូឡុង ជា រដ្ឋមន្ត្រីក្រសួង សេដ្ឋកិច្ច, លោក ប៉ាច ឈឺន ជា រដ្ឋមន្ត្រី ក្រសួង ផ្គត់ផ្គង់ស្បៀង និង ភស្តុការ, លោក ស៊ុម ហៀង ជា រដ្ឋមន្ត្រីក្រសួង មហាផ្ទៃ, លោក ឃីម ទិត ជា រដ្ឋមន្ត្រីក្រសួង ការពារជាតិ និង សុខាភិបាល។

## អ្នកណា ជា សត្រូវ នឹង អ្នកណា ?

នៅពេល បញ្ចប់ សង្គ្រាមលោក លើក ទី២ និង បរាជ័យ សង្គ្រាម ជប៉ុន ប្រឆាំងនឹង សហរដ្ឋអាមេរិក, កងទ័ព បារាំង ដឹកនាំ ដោយ ឧត្តមសេនីយ Leclerc ត្រូវបាន កងទ័ព សម្ពន្ធមិត្ត បញ្ជា ឱ្យមកត្រួតត្រា ការដកហូតអាវុធ កងទ័ព ជប៉ុន នៅ ឥណ្ឌូចិន។ មកដល់ កម្ពុជា ភ្លាម លោក Leclerc បញ្ជា ឱ្យចាប់ លោក សឺង ង៉ុកថាញ់ ហើយ បញ្ជូនលោក ទៅស្រុក បារាំង ជា បន្ទាន់ ហើយ ប៉ូលិស បារាំងសែស គេ តាម រកចាំ អ្នកទោស នយោបាយខ្មែរ ដែល ជប៉ុន បានដោះលែង។ ហ្លួង សីហនុ ព្រះ អង្គ ភ័យខ្លាច បារាំងចាប់ ក៏រត់ពួន តែ គិញ បារាំង គេ រក ឃើញព្រះអង្គ ហើយ នាំខ្លួន មកជួបលោក Leclerc, នរៈនោះ ទូល ព្រះអង្គ ថា បារាំង គេ មិន ដាក់ទោសពៃរ៍អ្វី ដល់ ព្រះអង្គ ដូចលោក សឺង ង៉ុកថាញ់នោះឡើយ ហើយ ព្រះអង្គ អាចបន្ត សោយរាជ្យសម្បត្តិ បាន។ បារាំង គេ ធ្វើបែបនេះ ព្រោះ គេ ចង់ រក្សាទាំងមូល សន្ធិសញ្ញា អាណាព្យាបាល បារាំង ជាមួយ ព្រះ មហាក្សត្រខ្មែរ នៅឆ្នាំ ១៨៦៣។ ដូច្នេះ ការិយកម្ម ជាបន្ទាន់ របស់គេ មាន ពីរយ៉ាង៖ ទី១ ស្វែងរក ភាពពេញច្បាប់ នៃ វត្តមាន របស់គេ នៅ កម្ពុជា, ទី២ គឺ កំទិចចោល សម្បុក នៃ អ្នកតស៊ូខ្មែរ នៅគ្រប់ហ្លក់។ ដូច្នេះ លោក សឺង ង៉ុកថាញ់ គាត់ បន្ត ជា ពៃរី[15] នឹង អាជ្ញាធរថ្មី របស់ បារាំង ព្រោះ គេ ចោទ

[15] ពៃរី៖ ន. បច្ចាមិត្ត។

# ខ្មែរឥស្សរៈ

លោក ជា អ្នកសហការ នឹង ទព័ជប៉ុន ប្រឆាំងនឹង បារាំង។ តែ លោក Leclerc គាត់ ធ្វើ ជា ភ្លេច ថា អាជ្ញាធរ បារាំង នៅ ឆ្នាំ ១៩៤២ ជា អ្នកសហការ ជា មួយ របប Vichy ដែល ជា សត្រូវ នឹង កងទ័ព របស់លោក ហើយ ហ្លួង សីហនុ ដែល អាជ្ញាធរនោះ ជា អ្នកតែងតាំង ព្រះអង្គ ជា មហាក្សត្រខ្មែរ ដោយ បំពាន រាជប្រពៃណី ពាក់ព័ន្ធនឹង សិទ្ធិ ឡើង គ្រងរាជ្យសម្បត្តិ បន្ត ពី លួង សវណ្ណកោដ្ឋ នៅក្នុង រាជវង្សានុវង្ស នៅ ស្រុកខ្មែរ។ ប៉ុន្តែ នៅ ពេលនោះ ចំណង់ របស់បារាំង ចង់យក ឥណ្ឌូចិន ជា ដែនដី អាណានិគមនិយម របស់ខ្លួនវិញ វា ប្រជំនឹង គោលការណ៍ របស់ មហាអំណាច ជា អ្នកឈ្នះ សង្គ្រាម លោកលើក ទី២ គឺ សហរដ្ឋអាមេរិក និង សហភាពសូវៀត ដែល មិនចង់ ឱ្យមាន អាណានិគមនិយម រស់ឡើងវិញ នៅលើ ពិភពលោក។ ៥០ ប្រទេស ស្ថាបនិក នៃ អង្គការ សហប្រជាជាតិ[16] (អ.ស.ប.) បាន ចារ ជា គោលការណ៍គ្រឹះ នៅក្នុង ធម្មនុញ្ញ នៃ អង្គការនេះ អំពី សិទ្ធិ នៃ ប្រជាពលរដ្ឋ សម្រេច ជោគវាសនា ដោយ ខ្លួនឯង ដែល ជា គោលការណ៍ ប្រឆាំង ដោយប្រយោលនឹង ការប៉ុនប៉ង ជា ថ្មី នៃ មស្ចឹមប្រទេស យកដែនដី អាណានិគមនិយម របស់ ខ្លួន មកកាន់កាប់វិញ។ សហភាព សូវៀត ដែល ជា លោក កុម្មុយនិស្ត មាន ទស្សនៈ បង្កើត ពិភពលោក តែ មួយ ឬ ឯក

[16] អង្គការ សហប្រជាជាតិ (អ.ស.ប.) បង្កើតឡើង នៅ ថ្ងៃ ទី២៥ មិថុនា ឆ្នាំ ១៩៤៥។

ភាព នៃ ពិភពលោក (One word) ដឹកនាំ ដោយ បក្សកុម្មុយនិស្ត។ ទស្សនៈនេះ ទង្គិចនឹង គោលការណ៍ នៃ លទ្ធិប្រជាធិបតេយ្យ ដែល មាន សហរដ្ឋអាមេរិក ជា អ្នកការពារ។ នៅក្នុង អំឡុងឆ្នាំ ១៩៤៥ ដល់ ១៩៥៤ ការប្រឈមមុខដាក់គ្នា រវាង មហាអំណាច ទាំងពីរនេះ បង្កើត ជា សង្គ្រាម ត្រជាក់ ដែល ធ្វើឱ្យ ប្រទេស ទន់ខ្សោយ បារម្ភ ព្រោះ មិនដឹង ត្រូវជ្រើសយកខាងណា។ នៅក្នុង អំឡុងពេលនោះ កាលបរិច្ឆេទពីរ ជា របត់សំខាន់ នៃ ព្រឹត្តិការណ៍ លើ ពិភពលោក គឺ ទី១ ការបង្កើត សាធារណរដ្ឋចិន ប្រជាមានិត នៅ ថ្ងៃទី ១ តុលា ឆ្នាំ ១៩៤៩ និង ទី២ កិច្ចព្រមព្រៀង នៅ ទីក្រុង ហ្សឺណែវ រវាង បារាំង នឹង យួនយៀកមិញ ដោយ មាន ប្រទេសចិន ប្រជាមានិត, សហភាពសូវៀត និង សហរដ្ឋអាមេរិក ទទួលយល់ព្រម។ ចិនកុម្មុយនិស្ត ចូលប្រឡូក លើ ឆាកអន្តរជាតិ ហើយ ធ្វើ សម្ព័ន្ធមេត្រី នឹង សហភាពសូវៀត នាំ បង្ហាញ នូវ រូបភាព នៃ លោកកុម្មុយនិស្ត អបរាជ័យ នៅចំពោះមុខ លោកសេរី។ តែ បន្តិចម្តងៗ ចិនកុម្មុយនិស្ត អះអាង អធ្យោត្តមភាព របស់ខ្លួន លើ ទឹកដី នៃ បរិមណ្ឌល, តាំឡើង សម្លេង និង ប្រាថ្នា ឱ្យខ្លួន មាន វត្តមាន សព្វអន្លើ លើ ឆាកអន្តរជាតិ ដែល នាំឱ្យមាន ការទាស់ប្រឆាំង គ្នា នឹង សហភាពសូវៀត។ ទំនាស់ លើ មនោគមវិជ្ជា និង សំដីទ្រគោះ រវាង មហាអំណាច កុម្មុយនិស្ត ទាំងពីរនោះ នាំ សម្រាល នៃ តុល្យភាព អំណាច រវាង សហរដ្ឋអាមេរិក នឹង សហភាពសូ

វៀត នៅលើ ពិភពលោក។ គឺថា ឈរលើ ទំនាស់ប្រឆាំងគ្នានេះឯង ដែល សហរដ្ឋអាមេរិក យកមក រចនា នយោបាយ ការបរទេស របស់ខ្លួន ដើម្បី កំទិច ប្រតិព័ន្ធ (bloc) ចិន-រុស្ស៊ី។ មួយវិញទៀត ទំនាស់ ចិន នឹង រុស្ស៊ី នេះ ក៏ចោទ ជា សំនួរ លើ គោលលទ្ធិ របស់ សហភាពសូវៀត ស្តីពី ‹ ពិភពលោក តែមួយ › និង ‹ សាកលភាព នៃ អន្តរជាតិ[17] › ដែល ខ្លួន ប្រាថ្នា បង្កើត តើ វានឹងអាច ធ្វើឲបានសម្រេចបានដែរឬទេ ?

## គ្រូឡេច របស់ បារាំង

នៅក្នុង បរិបទ អន្តរជាតិ បន្ទាប់ ពី បញ្ចប់ សង្គ្រាមលោកលើកទី២, បារាំង ធ្វើ គ្រប់បែបយ៉ាង ដើម្បី រក្សា ចក្រភពអាណានិគមនិយម របស់ខ្លួន នៅលើ ពិភពលោក។ នៅ ស្រុកខ្មែរ កិច្ចសន្យាបណ្តោះអាសន្ន បញ្ចប់ សន្និសញ្ញា នៃ អាណាព្យាបាល បារាំងសែស បាន ចុះហត្ថលេខា នៅថ្ងៃ ទី៧ មករា ឆ្នាំ ១៩៤៦ រវាង បារាំង នឹង រាជរដ្ឋាភិបាល ដឹងនាំ ដោយ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីរ៉េត។ កិច្ចសន្យាបណ្តោះអាសន្ននោះ គឺ បើកសិទ្ធិ ឱ្យអាជ្ញាធរ បារាំងសែស មាន អំណាចរដ្ឋ នៅ ស្រុកខ្មែរ នៅក្នុង រយៈពេលអន្តរកាល ដែល ជា រយៈពេល រៀបចំ ឱ្យមាន ការបោះឆ្នោត ជ្រើសរើស សមាជិក នៃ សភាជម្មនុញ្ញ ដើម្បី តាក់តែង រដ្ឋធម្មនុញ្ញ។ គណបក្សនយោបាយ ជាច្រើន បាន

17 សាកលភាព នៃ អន្តរជាតិ : œcuménicité de l’internationale.

ចូលប្រកួត[18] ក្នុង ការបោះឆ្នោត នៅថ្ងៃ ទី១ កញ្ញា ឆ្នាំ ១៩៤៦។ គណបក្ស ដែល ទទួល បាន ចំនួន អាសនៈ ច្រើនដាច់ខាត គឺ គណបក្ស ប្រជាធិបតេយ្យ, គណបក្ស ជាប់លេងរៀងទី២ គឺ គណបក្ស សេរីភាព។ គណបក្ស ទី១ មាន គោលការណ៍ នយោបាយ បង្ខំ បារាំង ឱ្យ ប្រគល់ ឯករាជ្យ បរិបូរណ៍ ភ្លាម ដល់ ប្រជាជាតិខ្មែរ, ចំណែក ឯ គណបក្សទី២ ប្រកាន់យក គោល ជំហរ ធ្វើ សហការ ជាមួយ បារាំង មួយរយៈសិន ដែល ជា គោល ជំហរ របស់ ហ្លួង សីហនុ នៅពេលនោះ។ នៅថ្ងៃ ទី១៦ ឧសភា ឆ្នាំ ១៩៤៧[19] រដ្ឋធម្មនុញ្ញទី១ នៃ រាជាណាចក្រ កម្ពុជា បានចូល ជាធរមាន ប្រកាស ដោយ ហ្លួង សីហនុ ដែល មាន របប នយោបាយ ដឹកនាំ ជា របបរាជានិយម អាស្រ័យរដ្ឋធម្មនុញ្ញ, ទោះបីជា ព្រះអង្គ មិនពេញ ព្រះរាជហឫទ័យ ព្រោះ ថា ជា លើក ដំបូងហើយ របបដឹកនាំជាតិ កើតចេញ ពី ឆន្ទៈផ្ទាល់ របស់ ប្រជាពលរដ្ឋ ហើយ ផ្តល់ លទ្ធភាព ឱ្យ ជនខ្មែរ ដែល មិនមែន

---

18 ដូចជា គណបក្ស ប្រជាធិបេតយ្យ ដឹកនាំ ដោយ ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ យុត្តិវង្ស គណបក្ស សេរីភាព ដឹកនាំ ដោយទ្រង់ នរោត្តម នរិន្ទដេត គណបក្ស ខេមរប៉ុន្នការ ដឹកនាំ ដោយ លោកលន់ នល់ គណបក្ស តំកើងប្រជាជាតិ ដឹកនាំ ដោយ លោក យ៉ែម សំបូរ គណបក្សចំរើនជាតិ ដឹកនាំដោយ លោកជា ជិន កុក គណបក្ស ត្បូសានមានជ័យ ដឹកនាំ ដោយ លោក ម៉ៅ ចយ គណបក្ស រួមជាតិ គណបក្ស ប្រជាជន គណបក្សរូបសំបុកឃ្មុំ ដឹកនាំ ដោយ លោក ម៉ម សុទ្ធ គណបក្ស រូបកណ្ដៀវ និង រូបកណ្ដាប់ស្រូវ ដឹកនាំ ដោយ លោក សំ ញៀន។

19 ព្រះអង្គម្ចាស់ ស៊ីសុវត្ថ យុត្តិវង្ស ដែល ខ្មែរយើង ភាគច្រើន ទុក ជា បីតា រដ្ឋធម្មនុញ្ញ ទ្រង់ប្រឈួនរោគ សគត មួយ ខែ ក្រោយពីបានប្រកាសឲប្រើរដ្ឋធម្មនុញ្ញទី១នៃរាជាណាចក្រកម្ពុជា។

ជា ព្រះមហាក្សត្រ ឬ សមាជិក នៃ ព្រះរាជវង្សានុវង្ស អាច មាន អំណាច ដឹកនាំជាតិបាន។ បន្ទាប់មក មាន ការបោះឆ្នោត ជាសាកល នៅថ្ងៃ ទី២១ ធ្នូ ឆ្នាំ ១៩៤៧ ដើម្បី ជ្រើសរើស សមាជិក រដ្ឋសភា។ គណបក្សប្រជាធិបតេយ្យ បានទទួល អាសនៈ ច្រើនជាងគេ ដដែល ហើយ លោក អៀវ កើស បាន ត្រូវ តំណាងរាស្ត្របោះឆ្នោតឲលោក ធ្វើជា ប្រធានរដ្ឋសភា ដំបូង នៃ សភាជាតិខ្មែរ។ ដើម្បី សំរៃ ទំនាស់ចិត្ត នឹង ហ្លួង សីហនុ គណបក្ស ប្រជាធិបតេយ្យ ជ្រើស ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ វុត្ថាឆាយាវង្ស ជា ព្រះរាជវង្សានុវង្ស ជា នាយករដ្ឋមន្ត្រី[20]។ បន្ទាប់ ពី ព្រះអង្គ សុំលាលែង ពី តំណែង, គណបក្ស បាន តែងតាំង លោក ឈាន វ៉ម ជា នាយករដ្ឋមន្ត្រី[21]។ ក្នុង និតិកាល ទី១ នៃ សភាជាតិនេះ មាន ដំណើរ រអាក់រអួលណាស់ ព្រោះ ហ្លួង សីហនុ តែងតែ បំពាន អំណាច ជានិច្ច ដើម្បី រកប្រយោជន៏ខ្លួនផ្ទាល់។ ជាការពិត អ្វីដែល ព្រះអង្គ អាច ធ្វើបាន ព្រោះ ព្រះអង្គ មាន ការគាំពារ ពី អាផ្ទាជរ បារាំងសែស។ មកដល់ថ្ងៃ ទី១៧ កញ្ញា ឆ្នាំ ១៩៤៩ ហ្លួង សីហនុ បាន រំលាយ រដ្ឋសភានេះទៅ។ ការរំលាយនេះ វា មាន គោលដៅងងឹត របស់ បារាំង និង ហ្លួង សីហនុ គឺ ផ្តល់ នូវ លទ្ធភាព ឱ្យ ព្រះមហាក្សត្រ ចុះ ហត្ថលេខា (ថ្ងៃ ទី៨ វិច្ឆកា) ទទួលយក លក្ខន្តិកៈ នៃ កម្ពុជា ជា ប្រទេសឯករាជ្យ នៅក្នុង សហ

[20] ២៥/០៧/៤៧-២០/០២/៤៨។
[21] ០២/០១/៤៨-១៤/០៨/៤៨។

## ខ្មែរឥស្សរៈ

ភាពបារាំងសែស។ លក្ខន្តិកៈនេះ ប្រគល់សិទ្ធិ ឲបារាំង បន្ត គ្រប់គ្រង កិច្ចការ នយោបាយ, ការបរទេស, ការពារជាតិ, ហិរញ្ញវត្ថុ និង យុត្តិធម៌។ ថ្ងៃ ទី៣ មីនា ឆ្នាំ ១៩៥១ មាន ការបោះឆ្នោត ជា ថ្មី រើស សមាជិក សភាជាតិ។ គណបក្ស ប្រជាធិបតេយ្យ ទទួល ជ័យជំនះ ម្តងទៀត។ រដ្ឋសភា ថ្មីនោះ មិនបាន អនុម័ត កិច្ចព្រមព្រៀង របស់ ហ្លួង សីហនុ នឹង បារាំង ស្តីពី ការបញ្ចូល ស្រុកខ្មែរ ទៅក្នុង សហភាព បារាំងសែស។

នៅក្នុង គោលដៅងដឹត ដដែល បារាំង គេ អនុញ្ញាតឱ្យ លោក ស៊ឹង ង៉ុកថាញ់ វិលត្រឡប់មកស្រុកវិញ នៅ ថ្ងៃ ទី ១៣ តុលា ក្នុង ឆ្នាំ ដដែល។ អ្នកភ្នំពេញ ច្រើនកុះករ មានទាំង ព្រះសង្ឃ, អ្នករាជការ, បចុជ្ជន, យុវជន នាំគ្នា ធ្វើ ដំណើរ ទៅទទួលលោក នៅ ព្រលាន យន្តហោះ ដូច ជា វិរបុរសជាតិ។ គោលបំណង ងដឹត ជាថ្មី របស់បារាំង គឺ គេ ចង់ ឱ្យមាន សហការ រវាង ហ្លួង សីហនុ នឹង លោក សឹង ង៉ុកថាញ់ ដើម្បី បំបែក កម្លាំង គណបក្ស ប្រជាធិបតេយ្យ។ ប៉ុន្តែ ប្រជាប្រិយភាព របស់ លោក សឹង ង៉ុកថាញ់ វា ទង្គិចនឹង មជ្ឈត្តកភាព[22] ឬ ចរិតអញនិយម របស់ ហ្លួង សីហនុ តែម្តង, ដូច្នេះ នៅក្នុង ព្រះរាជហឫទ័យ ជ្រៅ របស់ ព្រះអង្គ ទ្រង់ ចាត់ទុក លោក ស៊ឹង ង៉ុកថាញ់ ជា សត្រូវ សក្តានុពល របស់ ព្រះអង្គ។ ដូច្នេះ ចំពោះ ព្រះអង្គ សម្ព័ន្ធភាព នឹង

[22] មជ្ឈត្តកភាព : ភាពទុកខ្លួនជាធ្មើមលើសគេ។

លោក សឺង ង៉ុកថាញ់ គឺ ពុំអាចមានបាន នោះឡើយ ទោះបី ជាគម្រោង របស់ បារាំង យ៉ាងណាក្តី។

## ខ្មែរឥស្សរៈ

លោក ប៉ុណ្ណចន្ទ ម៉ុល បន្ទាប់ពីជប៉ុន ចាប់បារាំង នៅ ឥណ្ឌូចិន នៅ ខែ មីនា ឆ្នាំ ១៩៤៥, ជប៉ុន បានឱ្យ ដោះលែង អ្នកទោស នយោបាយ ទាំងអស់ ដែល បារាំង ចាប់។ លោក ប៉ុណ្ណចន្ទ ម៉ុល បាន ចាកចេញ ពី គុក នៅ កោះត្រឡាច ត្រឡប់មក រស់នៅ ភ្នំពេញវិញ។ ប៉ុន្តែ ពេល ជប៉ុន ចាញ់ សង្គ្រាម ហើយ បារាំង វិល ត្រឡប់មក ឥណ្ឌូចិន វិញ អាជ្ញាធរ បារាំង គេ តាម រកចាប់ អ្នកទោស ដែល ជប៉ុន ដោះលែង។ បន្ទាប់ពីដឹងដំណឹង ថា បារាំង គេ ចាប់ លោក សឺង ង៉ុកថាញ់ លោក ប៉ុណ្ណចន្ទ ម៉ុល សម្រេច ចិត្ត រត់ភៀសចន្លៀសខ្លួន ទៅ ខេត្ត បាត់ដំបង។ ខេត្ត នេះ ជំនាន់នោះ ស្ថិត នៅក្រោម ការត្រួតត្រា របស់សៀម។ នៅ ទីនោះឯង ដែល ជា ដែន កំណើត នៃ ចលនា ខ្មែរឥស្សរៈ។ អ្នក ដែលមាន គំនិត ផ្តួចផ្តើម បង្កើត ចលនានោះ គឺ លោក ប៉ុក គុណ[23] ហៅ តាត្រឡាច ដែលត្រូវជាមា របស់លោក ប៉ុណ្ណចន្ទ ម៉ុ

[23] ប៉ុក គុណ ជា ចៅ របស់ លោក ប៉ុក អតីតរដ្ឋមន្ត្រី ទី១។ លោក ប៉ុក មាន កូនប្រុសពីរនាក់ ឈ្មោះ ប៉ុក ឌុច និង ប៉ុក ហែល និង កូនស្រី ម្នាក់ ឈ្មោះ ប៉ុក លួន។ អ្នកស្រី ប៉ុក លួន ជា ភរិយា របស់លោក ប៉ុណ្ណចន្ទ មងឃុន (អតិតអភិបាលស្រុក)។ លោក ប៉ុណ្ណចន្ទ មងឃុន គឺ ជា ឪពុក របស់លោក ប៉ុណ្ណចន្ទ ម៉ុល និង អ្នកស្រី ប៉ុណ្ណចន្ទ មូលី ជា ភរិយា របស់លោក ជួន ហ៊ល ដែល ជា កូន របស់សម្តេច ជួន វាំង។ អ្នកស្រី ប៉ុណ្ណចន្ទ មូលី ត្រូវជា ម្តាយ របស់លោក ជួន ជឿន, ជួន ជុំ, ជួន មុំ

ល។ ដូច លោក ប៉ុណ្ណចន្ទ ម៉ុល បានសរសេរ នៅក្នុង សៀវភៅ របស់គាត់ (ចារិតខ្មែរ) ថា ពាក្យ « ឥស្សរៈ » ជា ពាក្យ បាលី ដែលឱ្យន័យ ថា « ធំ, មិនកញ្ជះគេ, ជាអ្នកជា »។ ដូច្នេះ « ខ្មែរ ឥស្សរៈ » គឺ ក្រុមខ្មែរ ដែល ជា ម្ចាស់ លើ ខ្លួនឯង, គ្មាន នៅ ក្រោម អំណាច អ្នកណា, ជា ខ្មែរ មាន ឯករាជ្យ, សេរីភាព, សិទ្ធិ គ្រប់គ្រាន់ ជា ខ្មែរ។ ដូច្នេះ គោលបំណងជ្រៅ វា បង្ហាញ នៅក្នុង ន័យ នៃ ពាក្យ គឺ តស៊ូ ដើម្បី ឯករាជ្យជាតិ។ ប៉ុន្តែ ចលនានេះ វា អាស្រ័យ លើ សុច្ឆន្ទៈ នៃ សៀម ព្រោះ ខ្លួន ជ្រក នៅក្នុង ទឹក ដី សៀមកាន់កាប់។ មិនយូរប៉ុន្មាន រដ្ឋាភិបាលសៀម សំរេច ជួយ ឧបត្ថម្ភ ជា សម្ងាត់ ដល់ ចលនានោះ ដោយ អនុញ្ញាត ឱ្យបើក ជំរុំ ហ្វឹកហ្វឺន យោធា នៅ ឃុំ អន្លង់វិល ចម្ងាយប្រមាណ ជា ៥ គ.ម. ពី ក្រុង បាត់ដំបង។ គោលបំណងចម របស់សៀម គឺ គេ រៀបចំ យក ចលនានោះ ជា ជួរទី១ នៃ ការប្រឆាំងនឹង បារាំង ដែលនឹងអាច វិលត្រឡប់ មក កាន់កាប់ ទឹកដីខ្មែរ ដូច ជា ខេត្ត បាត់ដំបង, សៀមរាប, ពោធិសាត់ ដែល គេ ហួង យក នៅពេល ជប៉ុន កាន់កាប់ ទឹកដី ឥណ្ឌូចិន ព្រោះ សៀម នៅ ពេលនោះ ជា សម្ពន្ធមិត្ត នឹង ជប៉ុន[24]។ ក្នុងពេលដំណាលគ្នា

---

និង ជួន ប្រាសិទ្ធ និង អ្នកស្រី ជួន ដើម ដែល ជា ភរិយា របស់លោក ឈាន វ៉ម។

[24] ទឹកដីនេះ សៀម គេ ធ្លាប់ ចូលមកត្រួតត្រា រួចម្តងហើយ នៅមុន សម័យ អាណាព្យាបាលបារាំងសែស។ ប៉ុន្តែ ពេលបារាំង ចូលមក ត្រួតត្រា ស្រុក បារាំង បានទាមទារ ពី សៀម មកឱ្យខ្មែរវិញ នៅឆ្នាំ ១៩០៧។ តែ នៅពេល បារាំង ច្បាំងចាញ់ អាឡឺម៉ង់ សៀម គេ ចូលមក

នោះដែរ សៀម ធ្វើ ការឃោសនា ឱ្យនាយទាហានរងខ្មែរ ធ្វើការបំរើបារាំង ឱ្យរត់ចោល រាជការសឹក មកចូលធ្វើការ នៅក្នុងកងទ័ពសៀម ដោយ សន្យា នឹងតម្លើង សក្តិយស។ នៅពេលនោះ មាន ដាប ឈួន ដែលជា នាយទោ (caporal) ក្នុង កងទ័ពខ្មែរ បំរើបារាំង បាន រត់ចេញពីជួរទ័ព មកបំរើសៀម ដោយសង្ឃឹម ថា សៀម នឹងតម្លើង ឱ្យពាក់ ជា អនុសេនីយត្រី, តែ វាជា សេចក្តីសង្ឃឹម ស្រកោក ព្រោះ សៀម មិនគោរព ពាក្យសន្យារបស់ខ្លួន ដែល នាំឱ្យ លោក ដាប ឈួន អាក់អន់ស្រពន់ចិត្តជា ខ្លាំង ហើយ មាន គោលបំណង រត់ចេញពីសៀម នៅថ្ងៃណាមួយ ព្រោះ រស់បំរើសៀម មានការពិបាកណាស់ ទាំងផ្លូវ ការរស់នៅ និង ផ្លូវចិត្ត។ ដឹងតំណឹងនេះ ពួក ខ្មែរឥស្សរៈ លួចទាក់ទងនឹង ដាប ឈួន ដើម្បី ប្រមូល កម្លាំង អ្នកតស៊ូខ្មែរ។ នរៈនោះ ក៏លួចភៀសខ្លួនចេញ ពីសៀម ពី ឃុំ ស្វាយចេក មក ជ្រក ដោយសម្ងាត់ នៅក្នុង ជួរ ខ្មែរឥស្សរៈ នៅ អន្លង់វិល។ ត្រូវដឹងថាទោះបី ចលនា ខ្មែរឥស្សរៈ មាន ការឧបត្ថម្ភ ពី សៀម តែចលនានេះ មាន ស្វ័យភាព ច្រើនណាស់ ចំពោះមុខ អាជ្ញាធរសៀម ព្រោះ ចលនានោះ ប្រមូលបាន អ្នកតស៊ូខ្មែរ ច្រើន ដែលសៀម គេ គិត ថា វានឹងអាច មាន ប្រយោជន៏ ដល់គេ នៅពេលណាមួយមិនខាន។ ក្រោយមក ខ្មែរឥស្សរៈ ធ្វើ សកម្មភាព

---

ត្រួតត្រាវិញ ព្រោះ សៀម ព្រោះ បារាំង នៅ ឥណ្ឌូចិន គ្មាន លទ្ធភាព នឹង ការពារ ហើយ សៀម ជា មិត្ត របស់ អាឡឺម៉ង់ផង។

យោធា មួយចំនួន ដូចយ៉ាង វាយប្រហារទ័ពបារាំង[25] នៅ ក្រុង សៀមរាប នៅថ្ងៃ ទី៧ សីហា ឆ្នាំ ១៩៤៦។ ការវាយប្រហារ ក្រុង សៀមរាប នេះ ជា សញ្ញាទិស ចំពោះ បារាំង ថា ខ្មែរ ងើប តស៊ូ ដើម្បី ឯករាជ្យជាតិ និង ចំពោះ ប្រជាពលរដ្ឋខ្មែរ ថា មាន ចលនា តស៊ូ អាវុធ គឺ ខ្មែរឥស្សរៈ ដែល ខ្មែរម្នាក់ៗ អាចមក ចូលរួម, រំពឹង និង គាំទ្រ គ្រប់ មធ្យោបាយ ដែល អាចធ្វើបាន។ បន្ទាប់ ពី វាយប្រហាររួច កងទ័ព ខ្មែរឥស្សរៈ មិនវិលត្រឡប់មក មូលដ្ឋាន អន្លង់វិល វិញទេ ព្រោះ បារាំង បាន ចូលមកកាន់ កាប់ ខេត្ត បាត់ដំបង វិញ និង ទឹកដីខ្មែរ ដែល សៀម គេ ចូល មក កាន់កាប់។ ដើម្បី បន្ត ការតស៊ូ នៅតាម ព្រំដែន ខ្មែរ-សៀម ចលនា ខ្មែរឥស្សរៈ បំបែក ជា ៣ ក្រុមៈ ក្រុមទី១ មាន លោក ដាប ឈួន ជា មេ, ដកខ្លួនថយ ជា ក្រុម ទៅតាំងទីទ័ព នៅ ភ្នំគូលែន, ក្រុមទី២ មាន លោក ហែម សាវាង និង សា រូ ជា មេ, ក្រុមទី៣ មាន លោក រស់ យឿន ជា មេ, នាំគ្នា ទៅតាំងទី ទ័ព នៅ ស្វាយចេក, តែ នៅទីនោះ សៀម គេ ចាប់ លោក រស់ យឿន និង បូរិន យក ទៅ សម្លាប់ នៅ ប៉ោយ ប៉ែត។ រឿង សម្លាប់នោះ គ្មាននរណាម្នាក់ ដឹងថា មកពី ហេតុអ្វីនោះឡើយ។

ត្រូវដឹងដែរ ថា នៅ ទសវត្ស ៤០ ពេល កងទ័ព ជប៉ុន គេ ចូល មក ស្រុកខ្មែរ ជប៉ុន គេ បង្កើត « ទាហាន ស្ម័គ្រចិត្ត » នៅក្នុង

---

[25] ទាហានខ្មែរ បំរើក្នុង កងទ័ពបារាំង ខ្មែរយើងនៅសម័យនោះ ហៅថា ទាហាន ជើងខ្មៅ។ ជើងខ្មៅ ព្រោះ រុំកជើង ដោយ សំពត់បួពណ៌ខ្មៅ។

# ខ្មែរឥស្សរៈ

ក្របខណ្ឌ «មហា អាស៊ី»។ នៅពេល មាន ស្ដេចមួយអង្គ ព្រះនាម នរោត្ដម ចន្ទ រង្សី បាន ស្ម័គ្រចិត្ដ ចូលធ្វើ ហ្វឹកហ្វឺន ជាសិស្ស នាយទាហាន ដែល មាន អនុសេនីយទោ ជប៉ុន ជា គ្រូ ឈ្មោះ TSOTOMU TADAKOMA។ នៅពេល បារាំង វិលត្រឡប់មកស្រុកខ្មែរ វិញ ទ្រង់ ចន្ទ រង្សី[26] និង ទាហាន ស្ម័គ្រចិត្ដ មួយចំនួន នាំ គ្នា រត់ទៅខេត្ដបាត់ដំបង ដូចលោក ប៉ុណ្ណចន្ទ ម៉ុល ដែរ[27]។ ដូច បាន ជំរាប ខាងលើ រួចមកហើយ នៅទីនោះ ដែល នាំគ្នា បង្កើត ចលនា ខ្មែរឥស្សរៈ ដែល មាន រដ្ឋាភិបាលសៀម គេ ជួយឧបត្ថម្ភ។ ហើយ នៅពេល សៀម គេប្រគល់ ខេត្ដ បាត់ដំបង និង សៀមរាម ឱ្យមកខ្មែរវិញ ទ្រង់ ចន្ទ រង្សី និង លោក ប៉ុក គុណ និង ប៉ុណ្ណចន្ទ ម៉ុល ត្រូវ ចលនា ខ្មែរឥស្សរៈ ជ្រើសតាំង ធ្វើ ជា តំណាង អន្ដរជាតិ របស់ ចលនា ក្នុង បេសកកម្ម ទាក់ទង នឹង អាជ្ញាធរថៃ និង ពួក ខ្មែរយៀកមិញ។

[26] នរោត្ដម ចន្ទ រង្សី នៅក្នុង ចលនា ខ្មែរឥស្សរៈ គេ ទុក ទ្រង់ ជា តំណាង ព្រះរាជវង្សានុវង្សខ្មែរ។

[27] នៅជំនាន់នោះ ឥស្សរៈជន សំខាន់ៗ ដែល ចូលរួមជំណែក បង្កើត ខ្មែរឥស្សរៈ សំខាន់ៗ មាន ឈ្មោះ ៈ ប៉ុក គុណ, អ្នកស្រី លាត មួន, ប៉ុណ្ណចន្ទ ម៉ុល, ហែម សារ៉ាំង, សារ៉ូ, នរោត្ដម ចន្ទ រង្សី, ឈាង, ចាន់ តោត្រែស, ផន ស៊ី, សារ៉ាំង វង្ស, រស់ យឿន, បូរិន, ហ៊ូ អ៊ុកសាន, ខាន់ ពុំ, ផុត នី, កែវ តក់, ចន្ទ សារ៉ាត, ដាប ឈួន, ស៊ីវ ហេង, មូល សម្បត្ដិ, អាចារ្យ ប្រេស, អាចារ្យ មាន, ប៉ុង ភឿន, ងួន ហុង, លាវ កែវមនី (ខ្មែរយៀកមិញ), អៀ ស៊ីចូវ, ពុត ឆាយ, អ៊ុច, គ្រូ អ៊ុម, ហុង ឈុន (ខ្មែរយៀកមិញ)។

## ខ្មែរយៀកមិញ

ខ្មែរយៀកមិញ[28] ជា ចលនា បង្កើត ដោយ គណបក្ស កុម្មុយនិស្ត ឥណ្ឌូចិន (គ.ក.ឥ.) ហៅ ថា រណសិរ្សឥស្សរៈ សម្ព័ន្ធឥស្សរៈ (UIF)[29]។ រណសិរ្សនេះ ដឹកនាំ ដោយ យួនម្នាក់ ជា សមាជិកបក្ស។ តាម ឯកសារខ្មែរ ថា យួននោះ ឈ្មោះ អន មាន រស់នៅខេត្ត កំពត បាន បួស ជា ភិក្ខុ ហើយ បន្ទាប់មក ជា គ្រូបង្រៀន ភាសា បាលី ដែល អ្នកតស៊ូខ្មែរ ហៅ អាចារ្យ មាន។ អាចារ្យ មាន ដូរ ឈ្មោះ ហៅ សឺង ង៉ុកមិញ។ ដូច្នេះ យួន អន មាន, អាចារ្យ មាន និង សឺង ង៉ុកមិញ ជា មនុស្ស តែមួយ។ បុគ្គលនេះឯង ដែល គ.ក.ឥ. គេ ឱ្យដឹកនាំ ចលនា យៀកមិញ នៅ ស្រុកខ្មែរ។ ត្រូវដឹងថា បានជាយួន គេដាក់ឈ្មោះ សឺង ង៉ុកមិញ ព្រោះយួនចង់ បង្កើតមនុស្សម្នាក់ ឱ្យគោរពធ្វើតាមយួន ឱ្យមានឈ្មោះ ដូចគ្នាទៅនឹងខ្មែរក្រោមម្នាក់ទៀត ឈ្មោះ សឺង ង៉ុកថាញ់ ដែល នៅពេលនោះ កំពុងលេចឮឡើងថា ជា ‹‹ អ្នកជាតិនិយម ››[30]។ ពាក្យ ‹‹ មិញ ›› ជា ពាក្យយួន មានន័យថា « ខ្លួន

---

[28] គណៈកម្មធិការដឹកនាំ ឬ រដ្ឋាភិបាល មាន សឺង ង៉ុកមិញ (ប្រធាន), ចាន់ សាម៉ៃ, ទូ សាមុត, កែវ មុនី, ចៅ យិន, ស៊ីវ ហេង, លាវ កែវមុនី, សុស ម៉ន។ ហើយនឹង សមាជិក សំខាន់ៗ មាន នន សួន, មី ផូ និង នៃ សារ៉ាន់។

[29] Unified Issarak Front.

[30] ដកស្រង់ពី សៀវភៅ លោក សាគូ សាម៉ុត -ប្រវត្តិសាស្ត្រ កម្ពុជា និង វរជន ខ្មែរ។ ក្នុង សៀវភៅ នោះ បានបញ្ជាក់ ថា ៈ ពត៌មានច្បាស់លាស់ពី ដឹង ង៉ុកមិញ ពុំអាចដឹងបានឡើយ ដោយហេតុថា បុគ្គលនេះ ជា

អ្នក» គឺថា «ឥស្សរៈ» នឹងឯង។ ត្រូវដឹង ថា នៅ ឆ្នាំ ១៩២៥ ង្វៀន អៃ កុក (ឈ្មោះពិត របស់ ហូ ជី មិញ) បាន បង្កើត បក្សសម្ព័ន្ធ ដើម្បី ឯករាជ្យ នៃ វៀតណាម ដែល មាន ឈ្មោះ កាត់ ជាភាសា យួន ថា «Viet Minh[31]» ខ្មែរ ហៅ ថា «យៀកមិញ[32]»។ ដូច្នេះ ជម្រើស ឈ្មោះ សឹង ង៉ុកមិញ នេះ គឺ យួន គេ ចង់ បំភាន់ ខ្មែរ ថា មាន ខ្មែរ កំណើត នៅ កម្ពុជាក្រោម ជា ឥស្សរជន កំពុង ដឹកនាំ ចលនា តស៊ូ ដើម្បី ឯករាជ្យ កូសាំងស៊ីន និង កម្ពុជា។ រណសិរ្ស នោះឯង ជា បុព្វបក្ស នៃ គណបក្ស ប្រជាជន បដិវត្ត កម្ពុជា ដែល មាន សឹង ង៉ុកមិញ ជា ប្រធានបក្ស និង គណបក្សកុម្មុយនិស្ត កម្ពុជា បង្កើតឡើង នៅឆ្នាំ ១៩៦០ ដែល ក្រោយមក មាន សាឡុត សរ ហៅ ប៉ុល ពត ជា អគ្គលេខាធិការ បក្ស។

ចារបុរស យួនកុម្មុយនិស្ត បង្កប់ខ្លួន ធ្វើការ នៅ ស្រុកខ្មែរ។ តាម របាយការណ៍ របស់ ក្រសួង សន្តិសុខបារាំង នៅឆ្នាំ ១៩៣២ មានខ្មែរម្នាក់ មានដើមកំណើត នៅ កូសាំងស៊ីន មកធ្វើជា អ្នកនេសាទត្រី នៅ បឹងទន្លេសាប។ ថាច់ ធឿន ជា សមាជិក គ.ក.ឥ. ទទួល ‹‹ បេសកកម្មនយោបាយ ›› បំរើ គ.ក.ឥ. នៅ កម្ពុជា ដល់ឆ្នាំ ១៩៣៦។ ឆ្នាំ បន្ទាប់មក ថាច់ ធឿន បានបួស ជា លោកសង្ឃ នៅ ខេត្ត តាកែវ ដល់ ឆ្នាំ ១៩៣៩ ក៏សឹក ចេញមកធ្វើមេ គ.ក.ឥ នៅ ស្វាយរៀង។ ក្រោយមក ថាច់ ធឿន បានប្តូរឈ្មោះមកជា សឹង ង៉ុកមិញ ជា ប្រធាន បក្សកុម្មុយនិស្តខ្មែរ លើកទី១ នៅ កម្ពុជា។

[31] Ligue pour l’Indépendance du Vietnam (Viet Minh) : ជាបក្សសម្ព័ន្ធ ប្រមូលផ្តុំ នៃ ពួក អ្នកជាតិនិយមយួន តែ បក្សសម្ព័ន្ធ ដឹកនាំ ដោយ គណបក្សកុម្មុយនិស្តយួន។

[32] ខ្មែរ ទម្លាប់ ហៅ ប្រទេស វៀតណាម ថា យៀកណាម ដូច្នេះ ពាក្យ វៀតមិញ ក៏ខ្មែរ នៅតែហៅ ថា យៀកមិញ។

# ខ្មែរឥស្សរៈ

នៅថ្ងៃ ទី ២៧ មេសា ឆ្នាំ ១៩៥៤, លោក កៅ តក់ ជា មេ ខ្មែរឥស្សរៈ មួយក្រុម បានចូលរួម ជាមួយ ខ្មែរវៀតមិញ មាន លាវ កែវមុនី និង ហុង ឈុន ជា នាយទ័ព ធ្វើការវាយប្រហារ ខ្សែរទេះភ្លើង បាត់ដំបង-ស៊ីសុផុន មួយខ្សែ ដោយបានធ្វើឱ្យ របួសអ្នកដំណើរ ជាច្រើន និង មាន ទាហានបារាំង ស្លាប់មួយចំនួន។ សកម្មភាព រួមគ្នា បែបនេះ វា មាន ជា ទូទៅ រវាង ខ្មែរឥស្សរៈ និង ខ្មែរវៀតមិញ ព្រោះ ជា ការរួបរួម នៃ មូលហេតុ នៅចំពោះមុខ សត្រូវរួម គឺ បារាំង។ ប៉ុន្តែ ក៏មាន ជំលោះ អាវុធ រវាងគ្នា ក៏ច្រើនណាស់ដែរ ព្រោះ ជា ទំនាស់ នៃ ផលប្រយោជន៍។

សហការ រវាង ខ្មែរឥស្សរៈ ជាមួយ ខ្មែរវៀតមិញ គឺ គេ បែងចែក ស្រុកខ្មែរ ជា ៤ តំបន់ គស្ង៉ៈតំបន់ អគ្នេយ៍ នៅក្រោមការត្រួតត្រា របស់ លោក កែវ មុនី[33], តំបន់ ឦសាន មាន លោក សីន ស៊ីចាន់ ជា មេដំបន់, តំបន់ និរតី ដឹកនាំដោយ លោក សឹង ង៉ុកមិញ និង តំបន់ ពាយ័ព្យ គឺ លោក ដាប ឈួន ជា ប្រមុខ។ តាម សេចក្តីរាយការណ៍ របស់ កិញបារាំង ទ័ពព្រៃ ប្រឆាំងនឹងបារាំង មាន ចំនួន ប្រមាណ ៥ ពាន់នាក់, តែ គ្មានកាំភ្លើងកាន់គ្រប់គ្នា នោះទេ ហើយ បែកបាក់គ្នាផង។ ហើយ នៅក្នុងកងទ័ព ទាំងឡាយនោះ មាន ជនជាតិ អឺរ៉ុប ៣ នាក់ និង ជប៉ុន ៦ នាក់។ ក្នុង កងទ័ពនោះ ខ្មែរឥស្សរៈ មាន ៨០០ នាក់, ទ័ព ខ្មែរវៀតមិញ មាន ៤៦០ នាក់, ទ័ព ចំរុះ ខ្មែរឥស្សរៈ និង

[33] លោក កែវ មុនី ជា ញាតិ នៃ ព្រះរាជវង្សានុវង្ស ក្នុង វង្ស ស៊ីសុវត្ថិ។

# ខ្មែរឥស្សរៈ

ខ្មែរយៀកមិញ មាន ៦៤០ នាក់, ទ័ព សៀម មាន ២១០ នាក់, ទ័ព កូនចិន មាន ២០០ នាក់, និង ក្រុម តូច ធំ ដទៃ មាន ចំនួន រាប់រយនាក់ទៀត។

មកដល់ឆ្នាំ ១៩៥២ រណសិរ្ស ខ្មែរយៀកមិញ ធ្វើសកម្មភាព យោធា នៅក្នុង ទឹកដីខ្មែរ ក្នុង ខេត្ត កំពង់ចាម, បាត់ដំបង, កំពង់ឆ្នាំ, កំពង់ធំ និង កំពត។ នៅពេល សន្និសិទ្ធ នៃ ទីក្រុង ហ្សឺណែវ នៅឆ្នាំ ១៩៥៤ រណសិរ្សនោះ ទាមទារ តាម សំណើរ របស់ លោក ផាំ វ៉ាន់ដុង, មេ គណៈប្រតិភូ យួនយៀកមិញ, ស្នើសុំឱ្យ ចែកស្រុកខ្មែរ មួយភាគ ឱ្យទៅ ពួក ខ្មែរយៀកមិញ ព្រោះ ពួក នោះ គេ ត្រួតត្រា ទឹកដីរំដោះ នៅកន្លែងនោះ ច្រើនជាងគេ។ ប៉ុន្តែ តំណាង នៃ ប្រទេស បារាំង, អង់គ្លេស និង អាមេរិកាំង បដិសេធ សំណើរនេះ តែ ចិនកុម្មុយនិស្ត និង សហភាពសូវៀត គាំទ្រ។ ត្រូវដឹងថា នៅពេល សន្និសិទ្ធ នៃ ទីក្រុង ហ្សឺណែវ, ខ្មែរ យើង ភាគច្រើន ដោយ ចាញ់បោក ការឃោសនា របស់ ហ្លួង សីហនុ នាំគ្នាយល់ឃើញ ថា ជា ជ័យជំនះ របស់ខ្មែរ ព្រោះ ស្រុក ខ្មែរ មិនត្រូវបាន គេ បែងចែក ជា ពីរ ដំបន់ ដូច ស្រុកយួន និង លាវ តែ ខ្មែរយើង ភ្លេច គិត ថា នៅពេលនោះ គេ បាន បញ្ចូល កម្ពុជាក្រោម ទាំងមូល ទៅក្នុង ទឹកដី យួន ខាងត្បូង ដែល គេ បង្កើតឡើង ហើយ ជនជាតិខ្មែរ នៅ កម្ពុជាក្រោម ក៏ ក្លាយទៅ ជា សញ្ញាតិយួន។

## ការបែកបាក់គ្នា

ដូច បានជំរាប ពី ខាងលើ ក្រោយ ពី ការវាយប្រហារ របស់ ខ្មែរឥស្សរៈ នៅ ទីក្រុង សៀមរាម ពួកនោះ បានបែកគ្នា ជា ក្រុមផ្សេងៗគ្នា គ្មាន ឯកភាព នៃ បញ្ជាការរួម។ ដើមឡើយ ជា ការបែងចែក ទឹកដី យុទ្ធសាស្ត្រ យោធា ដើម្បី វាយគ្នា សំរាប់ ធ្វើសកម្មភាព ប្រឆាំងនឹង ការវិលត្រឡប់ នៃ អាណានិគមនិយមបារាំង។ បន្តិចម្តងៗ ការបែងចែកនោះ វា ក្លាយ ជា ការបែកបាក់ ព្រោះ ខ្មែរឥស្សរៈ គ្មាន អង្គការ នយោបាយ ទោល សំរាប់ដឹកនាំ ការតស៊ូ នោះឡើយ។ នៅឆ្នាំ ១៩៤៩ លោក ដាប ឈួនសាកល្បង បង្កើត ចលនា រំដោះ ប្រជាពលរដ្ឋខ្មែរ (KPLC) ដែលមាន គាត់ ជា ប្រធាន និង លោក កៅ តក់ ជា អនុប្រធានហើយនឹង ទ្រង់ ចន្ទ រង្សី ចូលរួមផង ដើម្បី ប្រមូលផ្តុំ ក្រុម តូចធំ របស់ ចលនា ខ្មែរឥស្សរៈ ដែល ធ្វើ សកម្មភាព រៀងៗខ្លួន។ តែ បុគ្គល ដាប ឈួន ជា មនុស្ស កាចសាហាវ និង ផ្តាច់ការ, ដូច្នេះ ការបង្កើត រណសិរ្សនោះ មិនមាន គោលបំណង ប្រមូលកម្លាំង តស៊ូ នោះទេ គឺ គាត់ ចង់យក ចលនានោះ មកដាក់នៅក្រោម អំណាច របស់គាត់ផ្ទាល់ តែម្តង។ ជន រងគ្រោះ នឹងអំពើ ព្រៃផ្សៃ របស់ ដាប ឈួន នៅពេលនោះ គឺ លោក ហែម សាវ៉ាង និង សារូ, ដែល នរៈនេះ បញ្ជា ឱ្យលួចសម្លាប់ចោល នៅពេល ដែល អ្នកទាំងពីរ ធ្វើដំណើរ មក ភ្នំដងរែក ដើម្បី ចូលប្រជុំ បង្កើត ចលនា។ ការបែកបាក់គ្នានោះ វា មិនអាច ចៀស

បាន ព្រោះ ចលនា ខ្មែរឥស្សរៈ គ្មាន មូលដ្ឋាន នយោបាយ ពិតប្រាកដ ហើយ គ្មាន នយជន (អ្នកនយោបាយ) មានការពិសោធ សំរាប់ ដឹកនាំ នោះឡើយ។ ពិតណាស់ហើយ ថា មានអ្នកស្នេហាជាតិ និង អ្នកជាតិនិយម មាន ឆន្ទៈ ដ៏មុតមាំប្រឆាំងនឹង អាណានិគមនិយម បារាំង តែ ពួក អ្នកស្ម័គ្រចិត្តទាំងនោះ មិនបាន ទទួល ការអប់រំ នយោបាយ ដែល ជា សសរស្តម្ភ នៃ ការតស៊ូ ដើម្បី ឯករាជ្យជាតិ។ ចលនា ខ្មែរឥស្សរៈ នៃរលក ទី១ កើត ជា រូបរាង បាន ដោយសារ សៀម គេ ជួយ ក្នុងប្រយោជន៍សៀម ដែល គេ ត្រូវការ ដៃខ្មែរ កាន់អាវុធ តស៊ូដើម្បី រក្សា ទឹកដីខ្មែរ ដែល គេដណ្តើមបានវិញ នៅឆ្នាំ ១៩៤០ពីបារាំង។ ជា ឧទាហរណ៍ លោក កៅ តក់ ដែលជាមេ ខ្មែរឥស្សរៈល្បីម្នាក់ តែងតែ ដើរ ឃោសនា តាម សាលារៀន ជាមួយ សៀមម្នាក់ ឈ្មោះ ហរៃឌី ហើយ សៀមនោះ និយាយប្រាប់ កូនសិស្សខ្មែរ ថា « ពួកយើង ជា ថៃ ត្រូវ ជា បងប្អូននឹង ខ្មែរ ហើយ យើងត្រូវបែកបាក់គ្នា ដោយសារ អាណានិគមនិយម បារាំង។ ឥឡូវយើង ត្រូវ រួមគ្នាឡើងវិញ ដោយមាន ស្តេចថៃ ជា មេដឹកនាំរបស់យើង ទាំងអស់គ្នា »។ មួយវិញទៀត ចលនា ខ្មែរឥស្សរៈលើកទី១ នេះ មិនមែន ជា ការបន្ត នៃ ការតស៊ូនយោបាយតាមផ្លូវ អាវុធ របស់ វរជនសេរី ដែល បាន បង្កើត កាសែត« នគរវត្ត » នោះដែរ ដ្បិត វា គ្មាន ការភ្ជាប់ រវាង សកម្មភាពបញ្ញា ជាមួយ សកម្មភាព យោធា។ ត្រូវដឹងថា ការបារម្ភចម្បង

## ខ្មែរឥស្សរៈ

នៃ ចលនា ខ្មែរឥស្សរៈ នៅពេលនោះ គឺ រស់ដើម្បីរស់ សិន ព្រោះ ជីវិភាព រស់នៅ វា មាន កំពស់ ទាបណាស់ ហើយ ត្រូវពឹងផ្អែង ទាំងស្រុង ទៅលើ សៀម និង ឈ្មួញខ្មែរ ដែល គេ ជាអ្នករកស៊ី ជាមួយ សៀម ដូចជា លោកស្រី លៀត មួន លោក ប៉ុក គុណ និង កៅ តក់ ដែល ជា អន្តរការី តាម ផ្លូវការផង និង ផ្លូវ ងងឹតផង ជាមួយ អាជ្ញាធរ និង ឈ្មួញ សៀម។ សៀម គេ មិន ញញើត សម្លាប់ ខ្មែរ អ្នកតស៊ូ ណា ដែល គេ មើលឃើញ ថា ជា ជន ក្បាលរឹង ឬ ទទែ នឹងគេ។ កត្តា ដែល រៀបរាប់ ខាងលើនេះ ឯង ក៏អាចបញ្ចូលទៅ ក្នុង ហេតុផល ដែល នាំឱ្យ ចលនា ខ្មែរ ឥស្សរៈ បែកបាក់គ្នា ព្រោះ ក្រុម នីមួយៗ ស្វែង រក រស់ រៀងខ្លួន ដូច្នេះ ជួនកាល គេ មិនញញើត នឹងសម្លាប់គ្នា នោះឡើយ ដូច យ៉ាង ដាប ឈួន គាត់ បាន សម្លាប់ គូប្រជែងនឹងគាត់ច្រើន ណាស់ រួមទាំង លោក កៅ តក់ ដែល ជា ទន្ស្លមិត្ត នឹងគាត់។

### ចត្តមាន លោក សឺង ង៉ុកថាច់

ដូចបាន សរសេរ ខាងលើ រួចមកហើយ ថា នៅ ឆ្នាំ ១៩៥១ មាន ការបោះឆ្នោត ជា ថ្មី រើស សមាជិក សភាជាតិ, ហើយ រដ្ឋសភាថ្មី នោះ មានគណបក្ស ប្រជាធិបតេយ្យ ជា អ្នកឈ្នះ ដដែល ហើយ បន្ត ជំទាស់នឹង កិច្ចព្រមព្រៀង របស់ ហ្លួង សីហនុ នឹង បារាំង ស្តីពី ការបញ្ចូល ស្រុកខ្មែរ ទៅក្នុង សហភាព បារាំង, ដូច្នេះ រដ្ឋ សភាថ្មីនេះ មិនបាន អនុម័ត កិច្ចព្រមព្រៀងនោះឡើយ។ ហើយ នៅក្នុង គោលដៅងងឹត របស់ បារាំង គេ អនុញ្ញាតឱ្យ

# ខ្មែរឥស្សរៈ

លោក ស៊ឹង ង៉ុកថាញ់ វិលត្រឡប់មកស្រុកខ្មែរវិញ នៅ ថ្ងៃ ទី ១៣ តុលា ក្នុង ឆ្នាំ ១៩៥១ ដោយ សង្ឃឹម ថា លោក សឺង ង៉ុកថាញ់ អាចទៅ ជា តួ អាច បំបែកបាន កម្លាំង គណបក្សប្រជាធិបតេយ្យ ដោយ ធ្វើ សហការ ជាមួយ ហ្លួង សីហនុ។ ប៉ុន្តែ បារាំង មិនអាចស្មានបាន ថា ការផ្សះផ្សា រវាង បុគ្គល ទាំងពីរនេះ គឺ ជា បេសកកម្ម មិនអាចទៅរួច ដោយសារ ចារិត ផ្តាច់ការ របស់ ហ្លួង សីហនុ។ ឧកចិត្ត នឹង ចារិត របស់ សីហនុ ផង នឹង លែង មាន ឥទ្ធិពល លើ គណបក្សប្រជាធិបតេយ្យ ផង និង អំពើងងឹត ប៉ូលិស បារាំង នៅស្រុកខ្មែរ ប្រឆាំងនឹង អ្នកជាតិនិយម និង ការបិទ នៃ កាសែត របស់គាត់ នៅ ខែ កុម្ភៈ ឆ្នាំ ១៩៥១ ដែល គាត់ បង្កើត ឈ្មោះ « ខ្មែរក្រោក[34] » ផង, លោក សឺង ង៉ុកថាញ់ ជ្រើស យកផ្លូវ ថ្មីមួយទៀត គឺ រត់ចូលព្រៃ នៅថ្ងៃ ទី៩ មីនា ឆ្នាំ ១៩៥២ ដោយ សង្ឃឹម ថា នឹងអាច ធ្វើសហព័ន្ធ នៃ ក្រុម ខ្មែរឥស្សរៈ ទាំងឡាយ ដើម្បី បន្ត ការតស៊ូ អាវុធ ប្រឆាំង នឹង បារាំង។ លោក ចាកចេញ ពី ទីក្រុង ភ្នំពេញ ជាមួយ វរជនសេរី និង បញ្ញវន្ត មួយក្រុមតូច មាន លោក អៀ ស៊ីចូវ និង យុវបញ្ញវន្ត ដូចជា លោក ហង្ស ធុនហាក់[35] និង អ៊ីវ យ៉ាង នូវ យុវជនខ្មែរ មួយចំនួនទៀត ជា សិស្សានុសិស្ស អនុ

[34] កាសែត « ខ្មែរក្រោក » របស់ លោក សឺង ង៉ុកថាញ់ គឺ គាត់ ចង់បន្ត គោលការណ៍ នៃ កាសែត « នគរវត្ត » គឺថា ចង់ បង្កើនភាពភ្ញាក់ឡើង របស់ ពលរដ្ឋខ្មែរ ថា ស្រុកខ្មែរ មិនទាន់បាន ឯករាជ្យពិតប្រាកដទេ។

[35] ភរិយា របស់លោក ហង្ស ធុនហាក់ ជា កូនស្រីតែមួយ របស់ លោក កែវ តក់។

## ខ្មែរឥស្សរៈ

វិទ្យាល័យ និង វិទ្យាល័យ នាំគ្នា រត់ចូលព្រៃ ទៅតាមគាត់។ លោក សឹង ង៉ុកថាច់ យកបាន វិទ្យុផ្សាយសម្លេង មួយគ្រឿង ពីក្រសួង ឃោសនាការ ទៅជាមួយ។ លោក ទៅតាំង បញ្ជាការដ្ឋាន នៅតាមព្រំដែន ខ្មែរ-ថៃ ដោយមាន ការគាំទ្រ ជាបឋម ពី ក្រុម ឥស្សរៈ នៅតំបន់ សៀមរាប ដឹកនាំ ដោយ លោក កៅ តក់។ ក្រោយមក លោក សឹង ង៉ុកថាច់ បង្កើត វិទ្យុ សំរាប់ផ្សាយ ព័ត៌មាន និង ឃោសនា នយោបាយ ប្រឆាំងនឹង ការបន្ត វត្តមាន អាណាចរ បារាំង នៅស្រុកខ្មែរ។ លោក ហង្ស ធុនហាក់ ជា អ្នកធ្វើវិភាគ នយោបាយ ក្នុង នាម នៃ ចលនាថ្មី ដែល បង្កើតឡើង ក្នុង គោលបំណង បង្រួបបង្រួម ក្រុម ខ្មែរឥស្សរៈទាំងឡាយ ហៅ ថា « ចលនា ឥស្សរៈ រួមខ្មែរ បំរើជាតិ[36] »។ ចលនានេះ ធ្វើការអំពាវនាវ អញ្ជើញ ក្រុម ខ្មែរឥស្សរៈ ជា ច្រើនក្រុម ឱ្យមក ចូលរួម ធ្វើការប្រយុទ្ធរួម ដើម្បី ឯករាជ្យជាតិ។ ក្រុម មួយចំនួន បានសុខចិត្ត ចូលរួម មាន ក្រុម ទ្រង់ ចន្ទរង្សី, ពុត ឆាយ, រីឯ ក្រុម ខ្មែរឥស្សរៈ ដទៃទៀត នៅបន្តសកម្មភាព រៀងៗខ្លួន តែ ក៏ពុំទុកចលនាលោក សឹង ង៉ុកថាញ់ ជា សត្រូវ នោះដែរ។ ដូច្នេះ គោលបំណងចម្បង របស់លោក សឹង ង៉ុកថាញ់ ពុំបានសំរេចទាំងអស់ឡើយ។ ត្រូវដឹងថា លោក សឹង ង៉ុកថាញ់ គាត់ ធ្វើសហការ ជាមួយ ខ្មែរយៀកមិញ ច្រើនជាង

[36] គណកម្មធិការដឹកនាំ មាន សឹង ង៉ុកថាញ់, អៀ ស៊ី ចូវ, អាចារ្យ ខៀវ ជុំ, ហង្ស ធុនហាក់,អ៊ីវ យ៉ាង, ប៉េង គិត, ដួង ចាន់សារ៉ាត, កៅ តក់, សាង សាវ៉ាត, គាំ រ៉េត។

## ខ្មែរឥស្សរៈ

ខ្មែរឥស្សរៈ ដោយ លោក យល់ឃើញ ថា គ្រោះថ្នាក់ របស់ខ្មែរ គឺ មកពី ប្រទេសថៃ ច្រើនជាង មកពី ប្រទេសយួន។

## ទីចប់

ការចូលប្រលូក របស់លោក សឺង ង៉ុកថាញ់ នៅក្នុង ចលនា ខ្មែរ ឥស្សរៈ វា មិនស្របនឹង បរិបទ នយោបាយខ្មែរ នៅពេលនោះ ដែល កំពុងដើរ លើ ផ្លូវ លទ្ធិប្រជាធិបតេយ្យ ទោះបី នៅមាន វត្តមាន បារាំង នៅឡើយ។ ដូច្នោះឯង បានជា នយជនខ្មែរ ទាំងឡាយ នាំគ្នា ជ្រើសរើស មាគ៌ានោះ ដោយ មាន សេចក្តី សង្ឃឹម ថា ពិភពលោក មាន សណ្តាប់ធ្នាប់ថ្មី ឈរ លើ តម្លៃ នៃ សេរីភាព នៃ ប្រជាពលរដ្ឋ និង លទ្ធិប្រជាធិបតេយ្យ ដូច បាន ចែង នៅក្នុង ធម្មនុញ្ញ នៃ អ.ស.ប.។ ផ្លូវនេះឯង ដែល ប្រជា ពលរដ្ឋខ្មែរ អាចទាមទារ ឯករាជ្យ បរិបូរណ៌ ពី បារាំង បាន ដោយ មិនចាំបាច់ ប្រើ កម្លាំង អាវុធ។ ជ័យជំនះ គណបក្ស ប្រជាធិបតេយ្យ តាម អភិក្រម នៃ ការបោះឆ្នោតសាកល បញ្ជាក់ អំពី ជម្រើស នៃ អ្នកប្រជាធិបតេយ្យខ្មែរ ខុស ពី លោក សឺង ង៉ុកថាញ់ នៅពេល ដែល លោក សម្រេច រត់ចូលព្រៃ ដើម្បី កាន់ អាវុធ ប្រឆាំងនឹង បារាំង។

## ព្រះរាជបូជនីយកិច្ច

ការរត់ចូលព្រៃ របស់លោក សឺង ង៉ុកថាញ់[37] វា អាចទុកជា របត់ នៃ យុទ្ធសាស្ត្រ នយោបាយ ថ្មី របស់ ហ្លួង សីហនុ ដោយ មាន ជំនួយ ពី វរជនខ្មែរ មួយចំនួន ជា នយជន ជាញូជ័យ។ របត់ នោះ គឺ ហ្លួង សីហនុ ព្រះអង្គ ដើរតួផ្ទាល់ ជា អ្នកជាតិនិយម ដូចលោក សឺង ង៉ុកថាញ់ ប្រឆាំងនឹង បារាំង។ តួនាទីនេះ ក៏ជា ផ្លូវ នៃ ការដណ្ដើមយកផងដែរ នៃ អាវុធ នយោបាយ របស់ គណបក្ស ប្រជាធិបតេយ្យ[38] គឺ ការទាមទារ ឱ្យ បារាំង ប្រគល់ ឯករាជ្យ បរិបូរណ៏ ដល់ ប្រជាជាតិខ្មែរ។ ហ្លួង សីហនុ ព្រះអង្គ ត្រូវ ចាំបាច់ យកឈ្នះ គូសត្រូវ របស់ ព្រះអង្គ ក្នុងដែន នយោបាយ របស់ អ្នកទាំងនោះ តែម្ដង ដើម្បី ជា អាទិភាព ស្វែងរក ប្រជាប្រិយភាព របស់ទ្រង់ ក្នុងគោលបំណង ហួង អំណាច។ របត់នេះ ព្រះអង្គ ឱ្យឈ្មោះ ថា «ព្រះរាជបូជនីយកិច្ច[39]»។ រាជ

---

[37] តុលាការខ្មែរ ជំនាន់នោះ បាន កាត់ទោសប្រហារជីវិត និង កាត់ថ្លៃ ជំនួន ៣ លានរៀល បើសិន នរណា ចាប់ លោក សឺង ង៉ុកថាញ់ បាន។

[38] គោលការណ៏ នយោបាយ របស់ គណបក្ស ប្រជាធិបតេយ្យ នៅពេល នោះ មានបីយ៉ាង ទី១ ទាមទារឯករាជ្យជាតិ បរិបូរណ៏ ពី បារាំង, ទី២ ទាមទារ ឱ្យ បារាំង ទទួលស្គាល់ កម្ពុជាក្រោម ជា ទេកដី នៃ ប្រជាជាតិ ខ្មែរ, ទី៣ ទប់ទល់ ទុកជាមុន នៃ ឥទ្ធិពល ចលនា កុម្មុយនិស្តយួន នៅ ឥណ្ឌូចិន។

[39] ត្រូវកត់សំគាល់ថា នៅថ្ងៃ ទី១៦ មីនា ឆ្នាំ ១៩៥២ ថ្ងៃ ផ្ដើម ព្រះរាជបូជនីយ៏កិច្ចនេះ ទ្រង់ បានប្រើក ល្បិច ទំលាក់ រាជរដ្ឋាភិបាល នៃ គណបក្ស ប្រជាធិបតេយ្យ ដែល មាន លោក ហុយ កន្ធុល ជា នាយករដ្ឋមន្ត្រី ដើម្បីបង្កើត រដ្ឋាភិបាលថ្មី ដឹកនាំ ដោយ ព្រះអង្គផ្ទាល់ ក្នុងគោល បំណង ដណ្ដើម អំណាចរដ្ឋ។ បន្ទាប់មកទៀត ដើម្បី បំបាត់សម្លេង អ្នក ប្រជាធិបតេយ្យ ហ្លួង បាន រំលាយ រដ្ឋសភា នៅថ្ងៃ ទី១៣ មករា ឆ្នាំ

យុទ្ធសាស្ត្រថ្មីនេះ ហ្លួង សីហនុ ផ្ញើនយោបាយ ប្រមូលផ្តុំ គ្រប់ចលនា ប្រឆាំងនឹង បារាំង ដូចជា ចលនា ខ្មែរឥស្សរៈ និង ខ្មែរ យៀកមិញ។ ការអំពាវនាវ របស់ ហ្លួង សីហនុ នាំឱ្យ ក្រុម ខ្មែរ ឥស្សរៈ មួយចំនួន ដាក់ អាវុធ ហើយ ចូលមករួបរួម ក្នុង ព្រះរាជបូជនីយកិច្ច។ ក្រុមខ្លះ ធ្វើក្នុង គតិស្នេហាជាតិពិត តែ ក្រុមខ្លះទៀត ធ្វើ ដើម្បី ប្រយោជន៍ ផ្ទាល់ នៃ មេដឹកនាំ ព្រោះថា មានក្រុម ខ្មែរឥស្សរៈខ្លះ បង្កើតឡើង ដោយ ក្រុមចោរ មាន កាំភ្លើង ពីរបីដើម នាំគ្នា ធ្វើសកម្មភាព ប្លន់ ប្រជាពលរដ្ឋ និង អ្នកធ្វើដំនួញ តែប៉ុណ្ណោះ ដូច្នេះ វា ជា ឱកាសមួយ ដល់ខ្លួន អាចរក ការលើកលែងទោស ពី សំណាក់ អាជ្ញាធររដ្ឋ[40]។

---

១៩៥៣ ហើយ ប្រកាស ប្រជាជាតិ មាន អាសន្ន ក្នុងគោលបំណង ដណ្តើម អំណាច នីតិបញ្ញត្តិថែមទៀត គឺថា អំណាចរដ្ឋទាំងអស់។ ដូច្នេះ ហ្លួង សីហនុ ក៏បានក្លាយ ជា មហាក្សត្រផ្តាច់ការ ដែល វា ផ្ទុយស្រឡះនឹង រដ្ឋធម្មនុញ្ញជាតិខ្មែរ។

[40] លោក ដាប ឈួន បាន ចុះចូលមក រាជរដ្ឋាភិបាលខ្មែរ នៅថ្ងៃ ទី១ តុលា ១៩៤៩ ហើយ ហ្លួង សីហនុ បានតែងតាំងគាត់ ជា មេបញ្ជាការ តំបន់ស្វ័យ័ត សៀមរាប ហើយ នៅឆ្នាំ ១៩៥២ នរជននេះ បាន ចូលរួម យ៉ាង សកម្ម ក្នុង ព្រះរាជបូជនីយកិច្ច។ ក្រោយ ពីស្រុកខ្មែរ ទទួលបាន ឯករាជ្យ ដាប ឈួន ត្រូវបាន តែងតាំង ជា ចៅហ្វាយខេត្ត សៀមរាប ក្រោយមក នៅឆ្នាំ ១៩៥៧ ជា ទេសរដ្ឋមន្ត្រី ទទួលបន្ទុក សន្តិសុខជាតិ និង ធម្មការ។ ក្រោយមកទៀត នៅឆ្នាំ ១៩៥៩ អគ្គរដ្ឋទូតបារាំង នៅកម្ពុជា បានថ្វាយដំណឹងទៅ សម្តេច សីហនុ អំពី គម្រោងរដ្ឋប្រហារ របស់ ដាប ឈួន ជាមួយ សេអ៊ីអា។ នរជននេះ ដឹងថា គេ មកចាប់ ក៏រត់គេចខ្លួន ចូលព្រៃ តែត្រូវ នាយទាហាន របស់លោក បាញ់សម្លាប់ នៅក្នុងព្រៃ នៅថ្ងៃ ទី២១ កុម្ភៈ ឆ្នាំ ១៩៥៩។

## ខ្មែរឥស្សរៈ

បន្ទាប់ ពី ស្រុកខ្មែរ ទទួលបាន ឯករាជ្យ បរិបូរណ៍ នៅថ្ងៃ ទី៩ វិច្ឆិកា ឆ្នាំ ១៩៥៣ ក្រុម ខ្មែរឥស្សរៈ ផ្សេងៗ ក៏ដាក់អាវុធ ចុះចូល រាជរដ្ឋាភិបាល បន្តបន្ទាប់គ្នា ដូចយ៉ាង លោក ដាប ឈួន, កៅ តក់, ពុធ ឆាយ, សាវ៉ាង វង្ស ។ល។ ។ ទ្រង់ ចន្ទ រង្សី ចុះចូល នៅថ្ងៃទី ២០ កុម្ភៈ ឆ្នាំ ១៩៥៤ នៅបន្ទាយច្បារ ខេត្ត កំពង់ស្ពឺ ទទួលបានន្តរស័ក្តិ ជា វរសេនីយត្រី។ ទ្រង់ ដាក់អាវុធ យឺត ព្រោះ ទ្រង់ធ្វើ សហការ ជាមួយ ខ្មែរយៀកមិញ ដែល នៅពេលនោះ ពួកនោះ គ្មាន ហេតុផលអ្វី នឹង ដាក់ អាវុធចុះចូល រាជរដ្ឋាភិបាលខ្មែរ នោះឡើយ ព្រោះ កងទ័ព យួនយៀកមិញ គេ កំពុង វាយ កងទ័ព បារាំង នៅ ជុំរំយោធា បារាំង នៅ ឌីង បៀន ភូ (Diên Biên Phu)[41] ហើយ មាន ជ័យជំនះ នៅថ្ងៃ ទី៧ ឧសភា ឆ្នាំ ១៩៥៤។ យួនយៀកមិញ គេ រៀបចំ បញ្ចូល គណៈប្រតិភូ នៃ ចលនា ខ្មែរយៀកមិញ នៅក្នុង សន្និសិទ្ធ នៅទីក្រុង ហ្សឺណែវ ដើម្បី ទាមទារ បែងចែក ទឹកដីខ្មែរ ប្រគល់ឱ្យ ចលនា ខ្មែរយៀកមិញ, ដូច្នេះ យួន គេ ត្រូវការ ទ្រង់ ចន្ទ រង្សី ធ្វើ ជា តំណាង នៃ ព្រះរាជវង្សានុវង្សខ្មែរ នៅក្នុង គណៈប្រតិភូ ដែល មាន កែវ

---

41 សមរភូមិ នៅ ដំបន់ ឌីង បៀន ភូ ( ពីថ្ងៃទី ២០ វិច្ឆិកា ឆ្នាំ ១៩៥៣ ដល់ថ្ងៃ ទី៧ មីនា ឆ្នាំ ១៩៥៤)ស្ថិតនៅក្នុង តំបន់ តុងកឹង នៅក្បែរព្រំដែន យួន-លាវ រវាង កងទ័ព សហភាពបារាំង នឹង យួនយៀកមិញ ជា សមរភូមិ សំខាន់មួយ នៅក្នុង សង្គ្រាម នៅ ឥណ្ឌូចិន ហើយ ជា របត់មួយ ដែល បារាំង សុខចិត្ត ចុះហត្ថលេខា នៅក្នុង សន្និសិទ្ធ ទីក្រុងហ្សឺណែវ នៅថ្ងៃ ទី២០ កក្កដា ឆ្នាំ ១៩៥៤ បែងចែក ទឹកដីយួន បណ្ដោះអាសន្ន ឱ្យទៅយួនកម្មុយនិស្ត ព្រោះ បារាំង បានចាញ់សង្គ្រាម កងទ័ព យៀកមិញ នៅថ្ងៃ ទី ៧ មីនា ឆ្នាំ ១៩៥៤។

មុនី និង ម៉ី ផូ ជា សមាជិក និង ទ្រង់ ចន្ទ រង្សី ជា សមាជិបំរុង ប្រសិនបើ គណៈប្រតិភូនោះ គេ អនុញ្ញាត ឱ្យចូលរួមប្រជុំ។ ដូច្នេះ ទ្រង់ ចន្ទ រង្សី មាន គំរោង ទៅ ប្រទេស ស្វីស ដើម្បី បំរុង ខ្លួន ចូលប្រជុំ, ប៉ុន្តែ គណៈប្រតិភូ នៃ ចលនា ខ្មែរយៀកមិញ មិនបាន អនុញ្ញាត ឱ្យចូលរួមប្រជុំ។ គួរដឹងដែរថា នៅពេលនោះ យួនយៀកមិញ គេ មាន គោលបំណង យក ទ្រង់ ចន្ទ រង្សី ឱ្យដើរតួ ជា ព្រះអង្គម្ចាស់ Souphanouvong ដូចនៅ ស្រុកលាវ[42] ប្រសិនបើ សន្និសិទ្ទ សុខចិត្តបែកចែក ស្រុកខ្មែរមួយភាគ ឱ្យខ្មែរយៀកមិញ កាន់កាប់។ ដោយ ខ្វះ ការពិសោធនយោបាយ ទ្រង់ ចន្ទ រង្សី ធ្លាក់ ចូលក្នុង ឧបាយកល យួនយៀកមិញ។ រាជរដ្ឋាភិបាលខ្មែរ ដឹង រឿងសម្ងាត់នេះ ក៏ឱ្យ ប៉ូលិស ចាប់ខ្លួនទ្រង់ នៅ ប្រលានយន្តហោះ ពោធិចិនតុង ពីបទ « រួមគំនិតក្បត់នឹង ព្រះរាជបល្ល័ង្គ » និង ត្រូវបានយក ទៅដាក់ ពន្ធនាគារ។ បន្ទាប់រួចពី ពន្ធនាគារវិញ ទ្រង់ ចន្ទ រង្សី បានធ្វើជំនួញ ចិញ្ចឹមជ្រូក និង ជា ដង្ខៅឈើ ជាមួយលោក គាំ រ៉េត អតីត មេ ខ្មែរឥស្សរៈម្នាក់ នៅក្នុង ជួរ របស់ លោក សឺង ង៉ុកថាញ់[43]។

---

[42] នៅខែ កក្កដា ឆ្នាំ ១៩៥០, ព្រះអង្គម្ចាស់ Souphanouvong បង្កើត រដ្ឋាភិបាល បណ្តោះអាសន្ន នៃ ប្រទេស លាវ (Pathet Lao) ដោយ មាន ការគាំទ្រ ពីសំណាក់ យួនយៀកមិញ។

[43] មាន កំណែ (version) របស់លោក រស់ ចន្ទ្រាបុត្ត, អ្នកនិពន្ធ និង អ្នកកាសែត, ថារឿង ខាងលើនេះ ជា រឿងប្រឌិត សុទ្ធសាធ, រឿងពិត គឺជា រឿងស្នេហា កញ្ញាម្នាក់ ជា ប្អូនស្រី របស់មហេសី សម្តេច សីហនុ ឈ្មោះ

## ករណី លោក សឺង ង៉ុកថាញ់

លោក សឺង ង៉ុកថាញ់ មាន ឆន្ទៈនឹង ចុះចូល រាជរដ្ឋាភិបាល ដូច ក្រុម ខ្មែរឥស្សរៈ ផ្សេងៗទៀត ហើយ លោក ផ្ញើ សំណូម ជា ផ្លូវការ ថ្វាយ ដល់ សម្តេច តែ ព្រះអង្គ បដិសេធ ជា អហង្ការ ចំពោះ សំណើនោះ។ ការបដិសេធនោះ ជា គណនា នយោបាយ ប្រកបដោយល្បិច ទប់ស្កាត់ មិនឱ្យលោក សឺង ង៉ុកថាញ់ យក ប្រជាប្រិយភាព របស់លោក យកឈ្នះព្រះអង្គបាន តាម ការ បោះឆ្នោត ជាសាកល។ ចំពោះ ព្រះអង្គ សឺង ង៉ុកថាញ់ ជា ឧបសគ្គ ចុងក្រោយ លើផ្លូវ ឆ្ពោះទៅ រក អំណាចផ្តាច់ការ ដែល ព្រះអង្គ មាន ទម្រង់ការ តាំងតែ ពី ឆ្នាំ ១៩៤៦ មកម្លះ។ ជោគជ័យ នៃ ព្រះរាជបូជនីយកិច្ច ដែល នាំឱ្យ សម្តេច សីហនុ ក្លាយ ជា បិតា ឯករាជ្យជាតិ បរិបូរណ៍ វា អនុញ្ញាត ឱ្យព្រះអង្គ ទម្រុត ដោយងាយស្រួល នូវ គូនាទីសំខាន់ របស់លោក សឺង ង៉ុកថាញ់ លើឆាក នយោបាយជាតិ។ ខកចិត្តខ្លាំង លោក សឺង ង៉ុកថាញ់ ក៏ជ្រើសរើស ការបន្ត នៃ ការតស៊ូ ប្រឆាំងនឹង នយោបាយ ផ្តាច់ការ របស់ សម្តេច សីហនុ នៅតាម ព្រំដែន ខ្មែរ-សៀម រហូត ដល់ ឆ្នាំ ១៩៥៧។ បន្ទាប់មក លោក បានវិល

---

មុនីកេសនា ហៅ ម្ចាស់ដួង។ កញ្ញា មាន ឈ្មោះ វិរពង្ស ជា គូដណ្តឹង ទ្រង់ ចន្ទ រង្សី។ សម្តេច សីហនុ ក៏លួចស្រឡាញ់ កញ្ញានោះដែរ តែ ជា ស្នេហា អភ័ព្វ ព្រោះ កញ្ញានោះ គេ មិនបេតីនឹងព្រះអង្គ ដែល នាំឱ្យ ព្រះអង្គ ប្រឌិតរឿង ដើម្បី ចាប់ ទ្រង់ ចន្ទ រង្សី ដាក់គុក។ យើង មិនធ្វើអត្ថធិប្បាយ លើ កំណែ នេះឡើយ តែ យើង ក៏មិនយល់ស្របនោះដែរ។

ត្រឡប់ ទៅស្រុកកំណើត របស់លោកវិញ នៅ កម្ពុជាក្រោម។ នៅទីនោះ លោក បានបង្កើត ចលនា ខ្មែរសេរី ក្នុងគោលបំណង តស៊ូ ដើម្បី សេរីភាព ខ្មែរក្រោមផង និង បន្ត ប្រឆាំងនឹង សម្តេច សីហនុផង ដែល លោក ទុក ជា ជនផ្តាច់ការ។ ការណ៏នេះ វា ជា ទីចប់ នៃ ចលនា ខ្មែរឥស្សរៈ, នៅពេលនោះ លោក មាន អាយុ ៤៩ ឆ្នាំ។ ១៥ ឆ្នាំ ក្រោយមក នៅឆ្នាំ ១៩៧២ លោក លន់ នល់ ជា ប្រធានាធិបតី ដោយប្រកាសខ្លួនឯង នៃ សាធារណរដ្ឋខ្មែរ បានតែងតាំងលោក សឺង ង៉ុកថាញ់ ជា រដ្ឋមន្ត្រីទី១ នៅថ្ងៃ ទី២០ មីនា។ នៅក្នុង បរិបទ នយោបាយ ដ៏ ស្មុកស្មាញ បំផុត និង ការប៉ុនប៉ង ធ្វើឃាតលោក ពី សំណាក់ ពួកអនាមិក លោក ក៏ សុំលាពីតំណែង នៅថ្ងៃ ទី១៤ តុលា ឆ្នាំ ១៩៧២ ក្រោយពីមាន ការបោះឆ្នោត ជ្រើសរើស ប្រធានាធិបតី នៅថ្ងៃ ទី៤ មិថុនា ឆ្នាំ ១៩៧២ ហើយ លោក ក៏វិលត្រឡប់ មករស់នៅ កម្ពុជាក្រោម វិញ។ លោក ទទួលអនិច្ចកម្ម នៅក្នុងពន្ធនាគារ នៃ យួនកុម្មុយនិស្ត ឈ្មោះ ជីវ៉ា នៅឆ្នាំ ១៩៧៧ ក្នុងអាយុ ៦៩ ឆ្នាំ។ ការណ៏នេះ ក៏ជា ទីចប់ នៃ អត្ថកថា នៃ ជីវិតនយោបាយ របស់គាត់ផងដែរ៕

## ឯកសារយោង

Le Cambodge par Jean Delvert – Que sais-je, Collection Presses universitaires de France ;

Histoire du Vietnam par André Masson – Que sais-je, Collection Presses universitaires de France ;

Le Cambodge et la colonisation française par Alain Forest, L'Harmattan ;

Le temps des colonies – Les collection de l'histoire.

ឯកសារ របស់លោក ប៊ុន ថាន់ ;

ឯកសារ របស់លោក កេង វ៉ាន់សាក់ មួយចំនួន ;

ប្រវត្តិសាស្ត្រ កម្ពុជា និង វរជនខ្មែរ, សរសេរដោយលោក សាគូ សាម៉ុត, ភ្នំពេញ ២០១៣ ;

វិបត្តិកម្ពុជា, សរសេរដោយលោក សៅ ឆាត ;

ចរិតខ្មែរ, សរសេរដោយលោក ប៊ុណ្ណចន្ទ ម៉ុល។